

# ការប្តេជ្ញាផ្តល់ ប្រាក់កម្ចីទាក់ទង លំនៅដ្ឋានដល់អ្នក ដែលមានចំណូល ទាប និងមធ្យម

របាយការណ៍ ប្រចាំឆ្នាំ ២០១៦

FIRST FINANCE

# មាតិកា


០៤. សាររួមរបស់ប្រធានក្រុមប្រឹក្សាភិបាល និងអគ្គនាយិកា

០៦. អំពី ហ្វីស ហ្វាយនែន

០៨. សមិទ្ធិផលរបស់យើង

០៩. រឿងរបស់អតិថិជន

១០. យុទ្ធសាស្ត្ររបស់យើង

១១. រចនាសម្ព័ន្ធ ហ្វីស ហ្វាយនែន

១២. អំពីផលិតផល

១៣. រឿងរបស់អតិថិជន

១៤. ព្រឹត្តិការណ៍សំខាន់ៗប្រចាំឆ្នាំ ២០១៦

១៧. ហ្វីស ហ្វាយនែន លើសារព័ត៌មាន

១៨. ចំណាប់អារម្មណ៍បុគ្គលិក

១៩. ដៃគូវិនិយោគរបស់យើង

២០. របាយការណ៍របស់សវនកររាជ្យ

២២. របាយការណ៍ហិរញ្ញវត្ថុ

២៦. ក្រុមប្រឹក្សាភិបាល និងថ្នាក់ដឹកនាំ


តួរលេខក្នុងរបាយការណ៍នេះ គឺរបស់ ហ្វីស ហ្វាយនែន សម្រាប់ការិយបរិច្ឆេទ ០១ មករា ២០១៦ ដល់ ៣១ ធ្នូ ២០១៦

# សាររួមរបស់ប្រធានក្រុមប្រឹក្សា-ភិបាល និងអគ្គនាយិកា

នៅក្នុងឆ្នាំ២០១៦ កន្លងមកនេះ ហ្វីស ហ្វាយនែន នៅតែបន្តចក្ខុវិស័យរបស់យើង ក្នុងការជួយប្រជាជនកម្ពុជាដើម្បីសម្រេចក្តីបំណងក្នុងការមានផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន។ ក្នុងឆ្នាំនេះ ក្នុងនាមជាស្ថាប័នមួយក្នុងចំណោមស្ថាប័នដ៏តិចតួចក្នុងពិភពលោក ដែលមានទស្សនៈវិស័យបែបនេះ ពួកយើងនៅតែបន្តបោះជំហានទៅមុខ ដើម្បីកសាងកេរ្តិ៍ឈ្មោះ និងបំពេញបេសកកម្មរបស់យើងឲ្យកាន់តែប្រសើរ។ ជារៀងរាល់ឆ្នាំ ពួកយើងតែងតែឆ្ពោះឆិតកាន់តែជិតគោលដៅរបស់យើង ស្របពេលជាមួយគ្នានោះបញ្ហាប្រឈម និងរឿងរ៉ាវថ្មីៗក៏បានកើតឡើង ។ សម្រាប់ឆ្នាំនេះក៏មិនខុសប្លែកពីឆ្នាំកន្លងមកដែរ ។

យោងទៅលើរបាយការណ៍របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញ-វត្ថុនា ខែ សីហា ឆ្នាំ ២០១៦ ទីផ្សារអចលនទ្រព្យនៅតែបន្តទទួលរងឥទ្ធិពលពីកត្តា ២យ៉ាង គឺកត្តាផ្គត់ផ្គង់សម្រាប់តម្រូវការរស់នៅពិតប្រាកដ និង ផ្គត់ផ្គង់សម្រាប់តម្រូវការលក់យកប្រាក់ចំណេញ។ កត្តាទាំងពីរនេះនៅតែបន្តរងសម្ពាធក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ ។ ការធ្លាក់ចុះនៃផលិតផលកសិកម្ម បានប៉ះពាល់ដល់ចំណូលរបស់អតិថិជនគោលដៅរបស់យើង ហើយក្នុងខណៈពេលដែលមានការរីកចម្រើនផ្នែកសំណង់ តម្លៃផ្ទះ ដី និងគ្រឿងសំណង់ក៏ឡើងថ្លៃផងដែរ ។ យើងសង្ឃឹមថាបញ្ហាទាំងពីរនេះនឹងប្រសើរឡើងក្នុងឆ្នាំ២០១៨ ។

ហ្វីស ហ្វាយនែន ក៏ជួបប្រទះបញ្ហាកម្ចីមិនដំណើរការដូចជាស្ថាប័នមីក្រូហិរញ្ញវត្ថុដ៏ទៃទៀតដែរកាលពីឆ្នាំ២០១៦។ ទោះបីជាមានបញ្ហាប្រឈមដូចដែលបានរៀបរាប់ខាងលើក៏ដោយ ក៏ពួកយើងនៅតែបំពេញភារៈកិច្ចរបស់យើងក្នុងការការពារអតិថិជនរបស់យើងឲ្យបានច្រើនតាមការដែលអាចធ្វើទៅបាន ហើយនឹងធានាដល់ដៃគូវិនិយោគរបស់យើងថាភាគហ៊ុនរបស់ពួកគាត់ នៅតែបន្តរីកចម្រើនផងដែរ ។ បទពិសោធន៍ដែលយើងទទួលបានក្នុងឆ្នាំ២០១៦ បានជម្រុញឲ្យពួកយើង កាន់តែមានភាពច្នៃប្រឌិតក្នុងការធ្វើផែនការសម្រាប់ដំណើរឆ្ពោះទៅមុខបន្តទៀត ។

ដើម្បីឆ្ពោះទៅមុខបន្ត ពួកយើងនឹងពិនិត្យ ដើម្បីធ្វើឲ្យកាន់តែប្រសើរឡើងតាមវិធីសាស្ត្រមួយចំនួនដូចតទៅ៖

ជាបឋម យើងត្រូវតែស្វែងយល់ពីអតិថិជនរបស់យើងឲ្យបានកាន់តែច្បាស់ និងចូលរួមក្នុងការបំពេញតម្រូវការនិងដោះស្រាយបញ្ហាដែលពួកគេត្រូវប្រឈម ។ យើងត្រូវពិចារណាពីស្ថានភាពជាទូទៅរបស់ប្រជាជនកម្ពុជា និងស្វែងយល់ពីការគ្រប់គ្រងសេដ្ឋកិច្ចគ្រួសាររបស់ពួកគេ ។ ដើម្បីធ្វើការងារទាំងនេះ ពួកយើងបានទទួលយកបុគ្គលិកបន្ថែមដូចជាបុគ្គលិកបម្រើសេវាអតិថិជន បុគ្គលិកទីផ្សារតាមប្រព័ន្ធអ៊ីនធើណេត រហូតដល់ប្រធានផ្នែកបណ្តុះបណ្តាល ដើម្បីបំពេញចន្លោះផ្នែកធនធានមនុស្ស ។ បុគ្គលិកដែលចូលថ្មីទាំងនេះ នឹងជួយយើងផ្សាភ្ជាប់ទំនាក់ទំនងកាន់តែល្អជាមួយអតិថិជន ដើម្បីធានាថាពួកយើងនៅតែជាដៃគូដ៏ល្អសម្រាប់ពួកគេ និងសហគមន៍ដែលគេរស់នៅ។

ពួកយើងក៏កំពុងតែធ្វើអោយមានភាពប្រសើរឡើងទៅលើប្រសិទ្ធភាពការងាររបស់យើង តាមរយៈការធ្វើឲ្យដំណើរការអាជីវកម្មរបស់យើងមានភាពស្វ័យប្រវត្តិ និងមានបទដ្ឋានត្រឹមត្រូវ ដែលវានឹងផ្តល់នូវសេវាដ៏ប្រសើរដល់អតិថិជន និងគួរឲ្យទុកចិត្តបាន។ ពួកយើងក៏បានកែប្រែនីតិវិធីផ្តល់ប្រាក់កម្ចី និងផ្លាស់ប្តូរដំណើរការនៃផ្តល់កម្ចី ដើម្បីឲ្យកាន់តែមានភាពងាយស្រួល និងមានប្រសិទ្ធផល ។

ជាងនេះទៅទៀត ពួកយើងតែងតែផ្តោតលើផ្នែកខាងក្នុងរបស់យើង ក្នុងគោលបំណងពិនិត្យមើលថាតើមានអ្វីដែលយើងអាចធ្វើបានប្រសើរសម្រាប់បុគ្គលិក និង វប្បធម៌នៅក្នុងហ្វីស ហ្វាយនែន។ ការប្រកាន់ខ្ជាប់នូវបេសសកម្ម និងទស្សនៈវិស័យ ក៏ដូចជាការលើទឹកចិត្តដល់អ្នកដឹកនាំដែលមានភាពច្នៃប្រឌិត នឹងជម្រុញឲ្យយើងបន្តរដំណើរទៅមុខបានវែងឆ្ងាយ។

ជាចុងក្រោយក្នុងនាមជាក្រុមហ៊ុនមួយដែលកើតមានឡើងពីការវិនិយោគរបស់វិនិយោគិន ពួកយើងនឹងធ្វើការដោយប្រុងប្រយ័ត្នដើម្បីទទួលបានប្រាក់ចំណេញអតិបរមានិងធ្វើឲ្យមានហានិភ័យអប្បបរមាដើម្បីធានាឲ្យមានការរីកចម្រើននាពេលអនាគត។ ពួកយើងក៏បានធ្វើការជាមួយអ្នកជំនាញដែលផ្តល់ហិរញ្ញវត្ថុទាក់ទងនឹងផ្ទះសម្បែងនៅទូទាំងពិភពលោក ដើម្បីចែករំលែកអ្វីដែលយើងបានរៀនសូត្រ ខណៈនោះដែរយើងក៏បានស្វែងយល់ពីវិធីសាស្ត្រដែលពួកគេបានដោះស្រាយនៅពេលជួបនូវបញ្ហាប្រឈមក្នុងការផ្តល់នូវសេវាហិរញ្ញវត្ថុផ្នែកលំនៅដ្ឋាននៅតាមប្រទេសនីមួយៗ ដែលមានស្ថានភាពសេដ្ឋកិច្ចខុសគ្នា ។

ពួកយើងមានក្តីរំភើបសម្រាប់ការរីកចម្រើននាឆ្នាំកន្លងមក ហើយតាមរយៈបទពិសោធន៍ដែលយើងទទួលបានក្នុងឆ្នាំ ២០១៦ នឹងធ្វើឲ្យ ហ្វីស ហ្វាយនែន រឹងមាំជាងមុនក្នុងដំណើរឆ្ពោះទៅមុខរបស់យើង។



**Lee-Anne Pitcaithly**
ប្រធានក្រុមប្រឹក្សាភិបាល



**ជុន សុថានី**
អគ្គនាយិកា





បុគ្គលិក ហ្វីស ហ្វាយនែន កំពុងពន្យល់អំពី វិធីសាស្ត្របង់សង និងអត្ថប្រយោជន៍ផ្សេងៗទៀតទៅកាន់អតិថិជន

# អំពី ហ្វីស ហ្វាយនែន

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វីស ហ្វាយនែន ភីអែលស៊ី គឺជាក្រុមហ៊ុនដែលបណ្តាក់ទុនរួមគ្នារវាង ក្រុមហ៊ុន ហ្វីស ហូម ភីអែលស៊ី ដែលមានទីតាំងក្នុងប្រទេសកម្ពុជា Phillip Capital ដែលមានទីតាំងក្នុងប្រទេសសិង្ហបុរី Insitor Fund ដែលមានទីតាំងក្នុងប្រទេសលុចសំបួរ មូលនិធិអភិវឌ្ឍន៍កម្ពុជា ឡាវ ( Cambodia-Laos Development Fund ) និង Norfund ដែលមានទីតាំងក្នុងប្រទេសន័រវេស។ ហ្វីស ហ្វាយនែន បានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៩ ហើយបានក្លាយជាគ្រឹះស្ថានហិរញ្ញវត្ថុឯកទេស ក្នុងការផ្តល់ឥណទានផ្ទះសម្បែងមុនគេក្នុងប្រទេសកម្ពុជា។ ហ្វីស ហ្វាយនែន ផ្តោតយ៉ាងខ្លាំងទៅលើការផ្តល់ប្រាក់កម្ចីទិញផ្ទះ និងសាងសង់ផ្ទះរយៈពេលវែង ក៏ដូចជាកម្ចីអចលទ្រព្យធានារយៈពេលមធ្យមទៅដល់គ្រួសារដែលមានចំណូលទាប និងមធ្យម ដែលជាទូទៅពុំមានលទ្ធភាពប្រើប្រាស់សេវារបស់គ្រឹះស្ថានហិរញ្ញវត្ថុផ្លូវការនានា។

ក្រុមហ៊ុន ហ្វីស ហូម ភីអែលស៊ី ដែលជាក្រុមហ៊ុនស្ថាបនិក ហ្វីស ហ្វាយនែន បានធ្វើការសាកល្បង និងបានធ្វើឲ្យកាន់តែប្រសើរឡើងនូវគំនិតផ្តួចផ្តើមដំបូង ក្នុងការការផ្តល់ឥណទានផ្ទះសម្បែង ព្រមទាំងបានធ្វើការសិក្សាជាច្រើនទៅលើតម្រូវការទីផ្សារសម្រាប់ផលិតផលនេះ។ ទាំងនេះគឺជាមូលដ្ឋានគ្រឹះដែលនាំឲ្យ ហ្វីស ហ្វាយនែន រីកចម្រើនទៅមុខយ៉ាងឆាប់រហ័ស។

## អតិថិជនគោលដៅ

អតិថិជនគោលដៅរបស់យើងគឺជាប្រជាជនកម្ពុជាដែលមានចំណូលទាប និងមធ្យម ហើយមានឆន្ទៈចង់វិនិយោគទៅលើផ្ទះទីមួយរបស់គាត់។ ហ្វីស ហ្វាយនែន មានសាខាក្នុងរាជធានីភ្នំពេញ ខេត្តសៀមរាប បាត់ដំបង កំពង់ចាម នឹងបន្ទាយមានជ័យ ។ សាខាទាំងនេះក៏បម្រើសេវាទៅដល់ខេត្តកណ្តាល កំពង់ស្ពឺ ប៉ៃលិន ឧត្តរមានជ័យ និង ខេត្តត្បូងឃ្មុំផងដែរ ។



## ការកំណត់យកទីផ្សារគោលដៅ

ប្រជាជនកម្ពុជាភាគច្រើន មិនមានឱកាសទទួលបានសេវាហិរញ្ញវត្ថុផ្នែកផ្ទះសម្បែងជាផ្លូវការនោះទេ។ បច្ចុប្បន្នធនាគារជាច្រើនបានចាប់ផ្តើមផ្តល់កម្ចីទិញផ្ទះ ប៉ុន្តែសេវានេះត្រូវបានគេផ្តោតទៅលើអតិថិជនដែលមានជីវភាពធូធារតែប៉ុណ្ណោះ។

ហ្វីស ហ្វាយនែនផ្តល់កម្ចីទិញផ្ទះ និងសេវាកម្មជាក់លាក់ដែលឆ្លើយតបទៅនឹងតម្រូវការរបស់អតិថិជន ស្របជាមួយនឹងស្ថានភាពជាក់ស្តែងនៃប្រទេសកម្ពុជា។ អតិថិជនអាចជួបពិភាក្សាផ្ទាល់ជាមួយមន្ត្រីប្រឹក្សាឥណទានរបស់យើង ដើម្បីយល់ច្បាស់ពីផលិតផល ក៏ដូចជាដំណើរការផ្លូវច្បាប់ ទាក់ទងទៅនឹងការទិញផ្ទះលើកដំបូងនេះ។

## ទស្សនៈវិជ្ជាអាជីវកម្មរបស់យើង

ទស្សនៈវិជ្ជាអាជីវកម្មរបស់យើងមានភាពសាមញ្ញ ៖

**យើងគិតដូចជាអតិថិជន និងធ្វើខ្លួនដូចជាម្ចាស់**

វិធីសាស្ត្ររបស់យើងគឺកាន់តែងាយ ៖

- ផ្តល់នូវសេវានិងផលិតផលដែលឆ្លើយតបទៅនឹងតម្រូវការទីផ្សារ
- ផ្តល់នូវនីតិវិធីដែលមានភាពរហ័សនិងងាយស្រួល
- ធ្វើប្រតិបត្តិការប្រកបដោយភាពបត់បែន និងមានតម្លាភាព
- បង្ហាញពីភាពសុចរិតទៀងត្រង់ និងសីលធម៌ក្នុងការអនុវត្តអាជីវកម្ម

## ចក្ខុវិស័យរបស់យើង

ជួយឲ្យក្រុមគ្រួសារនៅក្នុងប្រទេសកម្ពុជា បានរស់នៅក្នុងសេចក្តីថ្លៃថ្នូរ សុវត្ថិភាព សុភមង្គល និងមានស្ថេរភាពតាមរយៈការផ្តល់លទ្ធភាពឲ្យពួកគាត់មានផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន ដោយមិនប្រកាន់ឋានៈ និងវណ្ណៈក្នុងសង្គមឡើយ

## បេសកកម្មរបស់យើង

ដើម្បីបង្កើតស្ថេរភាពសេដ្ឋកិច្ចនៃគ្រួសារកម្ពុជា ដែលមានចំណូលទាបតាមរយៈការផ្តល់លទ្ធភាព និងឱកាសក្លាយជាម្ចាស់កម្មសិទ្ធិនៃផ្ទះសម្បែង

## គុណតម្លៃរបស់យើង

**សុចរិតភាព**

ដើម្បីសម្រេចបាននូវចក្ខុវិស័យរបស់យើង យើងប្រកាន់ខ្ជាប់នូវភាពស្មោះត្រង់ និងមានតម្លាភាពគ្រប់សកម្មភាពការងាររបស់យើង ។

**ការឆ្លើយតប**

យើងតែងនៅកៀកស្និទ្ធជាមួយអតិថិជនគ្រប់គ្រាន់ល្មម ដែលអាចឲ្យយើងផ្តល់ការយកចិត្តទុកដាក់ និងឆ្លើយតបតម្រូវការរបស់ពួកគាត់ទាន់ពេលវេលា ។ យើងក៏មានទំនួលខុសត្រូវគ្រប់ទង្វើរបស់យើង និងបើកចិត្តទូលាយក្នុងការទទួលយកការរិះគន់ដើម្បីស្តាប់នាផងដែរ ។

**ភាពច្នៃប្រឌិតខ្ពស់**

យើងមានគំនិតច្នៃប្រឌិតខ្ពស់ ក្នុងការស្វែងរកដំណោះស្រាយដែលមានប្រសិទ្ធិភាពដើម្បីបម្រើអតិថិជនរបស់យើងឲ្យកាន់តែប្រសើរជាងមុន ។

**ភាពស្មើគ្នា**

យើងមានមោទនភាពចំពោះការគោរព ការមានជំនាញវិជ្ជាជីវៈច្បាស់លាស់ និងការបម្រើដល់អតិថិជនដោយស្មើភាព។

**ឧត្តមភាព**

ការងាររបស់យើងគឺធ្វើឡើងដោយអស់ពីកម្លាំងកាយចិត្ត។

# សមិទ្ធិផលរបស់យើង

នៅក្នុងឆ្នាំ ២០១៦ គឺជាឆ្នាំមួយដែលមានការប្រឈមដល់ការរីកចម្រើននិងប្រតិបត្តិការរបស់ ហ្វីស ហ្វាយនែន។ បញ្ហាដែលយើងបានជួប ទាំងនោះ គឺកើតចេញពីកត្តាខាងក្រៅនិងខាងក្នុង តែទោះជាយ៉ាងណាក៏ដោយ ក៏យើងនៅតែបន្តការប្តេជ្ញាចិត្តរបស់យើង ក្នុងការជួយដល់ក្រុមគ្រួសារដែលមានចំណូលទាប និងមធ្យមដែលត្រូវបានគេមើលរំលង ដើម្បីឲ្យពួកគាត់មានលទ្ធភាពបង្កើតនូវទ្រព្យធន និងស្ថេរភាពនៅក្នុងគ្រួសារ ។ គិតត្រឹមចុងឆ្នាំ២០១៦ ផលបត្រឥណទានរបស់យើងមានត្រឹម ១៩.៧លានដុល្លារ ដែលចំនួននេះមានការធ្លាក់ចុះ៨%បើធៀបទៅនឹងឆ្នាំ២០១៥។ អតិថិជនរបស់យើង ១៨% ជាប្រជាជនដែលរកចំណូលបានទាបជាង ៦ ដុល្លារក្នុងមួយថ្ងៃ និង ៣៨% ជាអ្នកដែលមានចំណូលទាបជាង ១២ដុល្លារក្នុងមួយថ្ងៃ។ ដើម្បីធ្វើឲ្យមានភាពប្រសើរឡើងក្នុងការគ្រប់គ្រងហានិភ័យលើប្រាក់កម្ចីមិនដំណើរការ ពួកយើងបានធ្វើការផ្លាស់ប្តូរគោលការណ៍សំវិធានធន ដែលគោលការណ៍នោះបានប៉ះពាល់ដល់ប្រាក់ចំណេញប្រចាំឆ្នាំរបស់យើង០.២លានដុល្លារ តែទោះជាយ៉ាងណា ពួកយើងមានអចលនទ្រព្យជាក់ស្តែងរបស់អតិថិជនជាទ្រព្យបញ្ចាំដែលខុសពីស្ថាប័នមីក្រូហិរញ្ញវត្ថុដ៏ទៃ។

ដោយមានការធ្លាក់ចុះនៃចំនួនផលបត្រ ចំនួនកម្ចីសកម្មរបស់យើងក៏បានធ្លាក់ចុះ៥% នៅសល់ត្រឹម ២,១៧៦ ហើយផលបត្រឥណទានបានសល់ត្រឹម ១៩,៦៩៣,៨៩៥ ដុល្លារ។ ចំនួនអតិថិជនជាស្ត្រីនៅតែរក្សាត្រឹម ៦១% នៃផលបត្រឥណទានរបស់យើងក្នុងឆ្នាំ២០១៦។ មាន៥២% នៃអតិថិ-ជនរបស់យើងជាអ្នកប្រកបរបរអាជីវកម្មផ្ទាល់ខ្លួន និងម្ចាស់អាជីវកម្មខ្នាតតូច។ ដោយសារស្ថានភាពមុខរបរ ភាគច្រើននៃពួកគាត់ទាំងនោះមានការលំបាកក្នុងការទទួលបានសេវាកម្ចីផ្លូវការពីស្ថាប័នផ្សេងៗ ។

ពួកយើងបម្រើសេវាដល់គ្រួសារកម្ពុជានៅតាមបណ្តាទីក្រុង និងខេត្តសំខាន់ៗ តាមរយៈសាខារបស់យើងនៅភ្នំពេញ សៀមរាប បន្ទាយមានជ័យ បាត់ដំបង និង កំពង់ចាម។ សាខាទាំងនេះក៏បម្រើសេវាដល់ខេត្ត កណ្តាល កំពង់ស្ពឺ តាកែវ ប៉ៃលិន ឧត្តរមានជ័យ និង ត្បូងឃ្មុំផងដែរ។

ហ្វីស ហ្វាយនែន នៅតែបន្តព្យាយាមឆ្ពោះទៅមុខដើម្បីសម្រេចគោលដៅរបស់យើងក្នុងការផ្តល់ដំណោះស្រាយហិរញ្ញវត្ថុផ្នែកលំនៅដ្ឋានឲ្យកាន់តែមានប្រសិទ្ធភាពដល់ក្រុមគ្រួសារកម្ពុជាដែលមានចំណូលទាប និងមធ្យម។









អ្នកស្រី សារង្ស និងស្វាមីឈរនៅខាងមុខផ្ទះរបស់ពួកគាត់

លោក ឡុង សារុធ និងភរិយារបស់គាត់ អ្នកស្រី ផាប់ សារង្ស បានផ្លាស់ទីលំនៅពីបន្ទាយមានជ័យមកសៀមរាបជាមួយនិងកូនប្រុសឈ្មោះ ឡុង ភីរ៉ា នៅក្នុងឆ្នាំ២០០១។ ពួកគេបានរស់នៅក្នុងបន្ទប់ជួលមួយនៅ ភូមិថ្នល់ សង្កាត់ស្រង៉ែ ក្រុងសៀមរាប។

ប្រាក់ចំណូលសរុបរបស់គ្រួសារបានប្រមាណ ៤២០ដុល្លារក្នុងមួយខែ ។ លោក សារុធ មានអាយុ ៥៥ឆ្នាំមានមុខរបរជាអ្នកបើកបរម៉ូតូកង់បី ដែលគាត់អាចរកចំណូលប្រមាណ ៣០០ ដុល្លារក្នុងមួយខែ ចំនែកឯកូនប្រុសរបស់គាត់មានអាយុ ២៦ឆ្នាំ ធ្វើជាបុគ្គលិកនៅសណ្ឋាគារអង្គរសិនជូរី ដែលគាត់មានប្រាក់ចំណូល១២០ដុល្លារក្នុងមួយខែ រីឯប្រពន្ធរបស់គាត់មានអាយុ ៤៨ឆ្នាំ ជាស្ត្រីមេផ្ទះ។

ពីមួយថ្ងៃទៅមួយថ្ងៃពួកគេបានសន្សំប្រាក់មួយចំនួនតូចដែលអាចទិញបានដីតូចមួយកន្លែងនៅភូមិ បុស្សក្រទ្បាញ់ សង្កាត់ជ្រៀវ ក្រុងសៀមរាប។ ពួកគាត់សប្បាយចិត្តណាស់ពេលបានដីមួយកន្លែងនោះ តែពួកគាត់ហាក់ដូចជាមិនមានវិធីណាដើម្បីសាងសងផ្ទះសោះ ។ ពួកគាត់បានពិភាក្សាគ្នាដើម្បីស្វែងរកជម្រើស នៃកម្ចីទិញផ្ទះដ៏ល្អបំផុតសម្រាប់គ្រួសារគាត់ ហើយចុងក្រោយគាត់ក៏សម្រេចចិត្តយកប្រាក់កម្ចីដែលមានទឹកប្រាក់ ៣,០០០ដុល្លារ ក្នុងរយៈពេល ៥ឆ្នាំ ចាប់តាំងពីថ្ងៃទី២៦ ខែមិនា ឆ្នាំ២០១៣ ដើម្បីសាងសងផ្ទះឈើតូចមួយនៅលើផ្ទៃដីទំហំ៨មគុណ២០ម ។ ក្តីបារម្ភរបស់ពួកគាត់បានកន្លងផុតទៅ ឯសុភមង្គលក៏ចាប់ផ្តើមមានច្រើនឡើងក្នុងរវាង ៤ ឆ្នាំនេះ ។ ពួកគាត់សប្បាយចិត្តនឹងរស់នៅក្នុងផ្ទះផ្ទាល់ខ្លួនរបស់ពួកគាត់ណាស់។ លោក សារុធ មានប្រសាសន៍ថា គាត់បានបង់ប្រាក់ថ្លៃឈ្នួលបន្ទប់ ៥០ដុល្លារក្នុងមួយខែជាឥតប្រយោជន៍ ។ គាត់បន្ថែមទៀតថា កាលពីគាត់រស់នៅក្នុងផ្ទះជួលគាត់មិនទទួលបានភាពសប្បាយរីករាយទេ ហើយក៏មិនមានបំណងធ្វើឲ្យមានបរិយាកាសប្រសើរឡើងអ្វីដែរ ព្រោះវាមិនមែនជាផ្ទះរបស់គាត់។

តែឥឡូវនេះគាត់បង់ប្រាក់ ៨០ដុល្លារក្នុងមួយខែដោយមានទំនុកចិត្តថានឹងបានផ្ទះផ្ទាល់ខ្លួននៅពេលចុងក្រោយ។គាត់បានកែប្រែផ្ទះរបស់គាត់ដែលពីមុនប្រៀបដូចជាវាលរហោស្ថានទៅជាកន្លែងដែលមានបរិយាកាសពេញទៅដោយរុក្ខជាតិខៀវខ្ចីនិងដើមឈើជាច្រើនប្រភេទ ហើយផ្លាស់ប្តូរពីកន្លែងដាច់ស្រយាលមួយឲ្យទៅជាកន្លែង ដែលមានបរិយាកាសរួសរាយរាក់ទាក់ជាមួយអ្នកជិតខាង។ ឥឡូវនេះប្រពន្ធរបស់គាត់អាចដាំបន្លែបន្តិចបន្តួចនៅមុខផ្ទះដែលអាចរកចំណូលសំរាប់គ្រួសារបានបន្ថែមទៀត រីឯកូនប្រុសរបស់គាត់វិញក៏បានការងារល្អជាងមុនដែរ។

បន្ទាប់មក ពួកគាត់បានយកកម្ចីបន្ថែមគឺកម្ចីអចលនទ្រព្យធា-នាដើម្បីទិញឡានមួយគ្រឿង សម្រាប់ដឹកភ្ញៀវទេសចរណ៍នៅក្រុងសៀមរាប ។ លើសពីនេះទៅទៀតទ្រព្យសម្បត្តិអចលន-ទ្រព្យរបស់គាត់បានកើនឡើងតម្លៃពី ៣,៦០០ដុល្លារ ដល់ ៩,៩០០ដុល្លារ ផងដែរ ។ មុខរបររបស់ពួកគាត់កំពុងរីកចំរើនរៀងខ្លួន ហើយពួកគាត់ក៏មានពេលវេលាល្អជាមួយគ្រួសារដោយបន្ថែមសមាជិកថ្មីម្នាក់ទៀត ជាប្រពន្ធរបស់លោក ភីរ៉ា រស់នៅក្រោមដំបូលផ្ទះដ៏កក់ក្តៅ និងសុវត្ថិភាព។

# យុទ្ធសាស្ត្រសម្រាប់ឆ្នាំ ២០១៧

ហ្វីស ហ្វាយនែន សម្លឹងទៅអនាគតដោយភាពវិជ្ជមាន ហើយក៏ផ្តោតការយកចិត្តទុកដាក់ទៅលើទីផ្សារផងដែរ។ ពួកយើងតែងតែរកវិធីក្នុងការធ្វើឲ្យប្រសើរឡើងនូវអ្វីដែលបានបំពេញក្នុងឆ្នាំ២០១៦ ក្នុងគោលបំណង ផ្តល់ប្រយោជន៍ដល់អតិថិជន បុគ្គលិក និង វិនិយោគិនរបស់យើង។

តាមរយៈមេរៀនដែលយើងបានឆ្លងកាត់ជាច្រើនឆ្នាំកន្លងមកនឹងធ្វើឲ្យមានការផ្លាស់ប្តូរពីរបៀបដំណើរការអាជីវកម្មរបស់ ហ្វីស ហ្វាយនែន នៅក្នុងឆ្នាំ២០១៧នេះ។

## ការឆ្លើយតបទៅអតិថិជន

នាពេលអនាគត ពួកយើងចង់ផ្តល់អត្ថប្រយោជន៍កាន់តែប្រសើរថែមទៀតដល់អតិថិជនរបស់យើង តាមរយៈការបន្ថែមសេវាដែលមានសារៈសំខាន់សម្រាប់ពួកគាត់ និង សម្រាប់ ហ្វីស ហ្វាយនែន ផងដែរ ។ អ្វីដែលពួកយើងអាចនឹងធ្វើមានដូចជា ផ្តល់ការប្រឹក្សាយោបល់ពីទីផ្សារអចលទ្រព្យ ផ្តល់ការប្រឹក្សាយោបល់សម្រាប់អាជីវកម្មខ្នាតតូច ផ្សាភ្ជាប់កិច្ចសហការជាមួយដៃគូរអាជីវកម្មរបស់យើង ដើម្បីផ្តល់សេវាពិសេសសម្រាប់អតិថិជន ឬក៏អាចជួយគ្រប់គ្រងហានិភ័យ។ ការទាំងនេះនឹងធ្វើឲ្យយើងក្លាយទៅជាដៃគូដំណោះស្រាយផ្នែកលំនៅដ្ឋានសម្រាប់អតិថិជនទាំងឡាយដែលយើងបម្រើ ។

បន្ថែមពីលើសេវាកម្មថ្មីទាំងនេះ ពួកយើងនឹងកសាងទំនុកចិត្តរបស់អតិថិជនមកលើយើងថែមទៀត ។ ភាពជាដៃគូជាមួយអតិថិជន និងសហគមន៍របស់យើង គឺជាមូលដ្ឋានយ៉ាងសំខាន់ក្នុងការបង្កើតផលិតផលថ្មីៗ ដែលផ្តល់ប្រយោជន៍ដល់ពួកគាត់ក៏ដូចជាការផ្តល់រង្វាន់លើកទឹកចិត្តដល់អតិថិជន និងសហគមន៍របស់យើងផងដែរ។

## ប្រសិទ្ធភាពដំណើរការអាជីវកម្ម

ដើម្បីផ្តល់ភាពងាយស្រួល និងបង្កើនប្រសិទ្ធភាពការងារដល់បុគ្គលិក និងក៏ដូចជាអតិថិជនរបស់យើង ហ្វីស ហ្វាយនែន មានផែនការដាក់ឲ្យដំណើរការប្រតិបត្តិការអាជីវកម្មដោយស្វ័យប្រវត្តិ។ ទាំងនេះមានដូចជា ដំណើរការឯកសារអេឡិចត្រូនិចក៏ដូចជាធ្វើឲ្យនិតិវិធី និងដំណើរការទាំងអស់មានបទដ្ឋានត្រឹមត្រូវនៅក្នុង ហ្វីស ហ្វាយនែន។ ការធ្វើបែបនេះនឹងជួយយើងក្នុងការប្រមូលព័ត៌មាន និង ចែកចាយព័ត៌មានកាន់តែមានគុណភាពខ្ពស់ និងមានភាពច្បាស់លាស់។ ពួកយើងក៏កំពុងរកវិធីសាស្ត្រដើម្បីលើកទឹកចិត្ត ដល់ការច្នៃប្រឌិតថ្មីៗថែមទៀតដែរ។ ក្នុងនាមជាក្រុមហ៊ុនមួយក្នុងចំណោមក្រុមហ៊ុនដែលតិចតួចលើពិភពលោក ពួកយើងកំពុងតែខិតខំស្វែងរកអ្វីថ្មីៗក្នុងវិស័យរបស់យើងជារៀងរាល់ថ្ងៃ។ ពួកយើងចង់រៀនសូត្របន្ថែមអំពីបទពិសោធន៍ដែលអតិថិជនទទួលបាន និងអ្វីដែលយើងអាចធ្វើឲ្យប្រសើរជាងមុន។

## ធ្វើអ្វីដែលយើងស្រម៉ៃចង់បាន

ពួកយើងចង់ក្លាយជាក្រុមហ៊ុនមួយ ដែលមនុស្សគ្រប់គ្នាប្រាថ្នាចង់ធ្វើការជាមួយ។ យើងចង់ជម្រុញបុគ្គលិកយើងឲ្យធ្វើអ្វីមួយដែលពួកគេបានគិតឡើង ថាជារឿងដែលអាចទៅរួច ។ យើងផ្តល់អត្ថប្រយោជន៍ដល់បុគ្គលិកដែលមានលក្ខណៈប្រកួតប្រជែង ដែលការផ្តល់នោះ គឺយោងទៅតាមសមត្ថភាពនិងទេពកោសល្យដើម្បីទាក់ទាញអ្នកមានទេព្យកោសល្យបន្ថែមពីខាងក្រៅ និងបង្កើនសមត្ថភាពបុគ្គលិកខាងក្នុងផងដែរ ។ ចំណែកឯបរិយាកាសប្រកបដោយភាពរួសរាយ និងការបំពេញការងារប្រកបដោយវិជ្ជាជីវៈរបស់យើង បានធ្វើឲ្យយើងមានភាពលេចធ្លោប្លែកពីដៃគូប្រជែង។

ដើម្បីបម្រើអតិថិជនយើងឲ្យកាន់តែប្រសើរ ពួកយើងចង់ប្រកាន់ខ្ជាប់នូវទស្សនៈវិស័យ និងបេសកកម្មរបស់យើងឲ្យបានកាន់តែខ្ជាប់ខ្ជួន ។ ពួកយើងចង់ឲ្យបុគ្គលិករបស់យើងទទួលបានអារម្មណ៍ថាទទួលបានជោគជ័យ នៅពេលដែលអតិថិជនរបស់យើង បានសម្រេចសុបិន្តក្នុងការទទួលបានផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន។ យើងធ្វើការដោយមានតម្លាភាព និងលើកទឹកចិត្តដល់បុគ្គលិកឲ្យមានភាពស្មោះត្រង់ក្នុងការរាយការណ៍ពីបញ្ហាទាំងឡាយដែលពួកគេប្រឈម ។

## ការពារមូលធន និងទ្រព្យសកម្ម

ផ្នែកចុងក្រោយនៃយុទ្ធសាស្ត្ររបស់យើង គឺការការពារផ្នែកហិរញ្ញវត្ថុអាជីវកម្មរបស់យើង ។ យើងនឹងព្យាយាមផ្តល់ប្រាក់ចំណេញជាអតិបរិមាដល់វិនិយោគិន និងម្ចាស់ភាគហ៊ុនរបស់យើង ជាមួយគ្នានេះដែរ យើងនៅតែរក្សាគុណភាពក្នុងការផ្តល់នូវបទពិសោធន៍ដ៏ល្អប្រសើរដល់អតិថិជន ក៏ដូចជាការគ្រប់គ្រងហានិភ័យឲ្យបានល្អផងដែរ ។ យើងនឹងព្យាយាមកាត់បន្ថយការចំណាយលើប្រតិបត្តិការរបស់យើង ឲ្យទាបបំផុតតាមការដែលអាចធ្វើទៅបាន តាមរយៈការគ្រប់គ្រងកម្ចីដែលមិនដំណើរការឲ្យមានប្រសិទ្ធភាព និងធ្វើឲ្យប្រាកដថាថ្នាក់គ្រប់គ្រងរបស់យើងមានគណនេយ្យភាពចំពោះលទ្ធផលនេះ។ យើងនឹងធានាឲ្យបានថា ព័ត៌មានគឺសុក្រឹតត្រឹមត្រូវសម្រាប់ដៃគូរបស់យើងទាំងអស់។ វិស័យរបស់យើង គឺជាវិស័យមួយដែលមានហានិភ័យ ហេតុនេះហើយយើងនឹងអភិវឌ្ឍន៍ អនុវត្តន៍នូវវិធី-សាស្ត្រដែលមានភាពប្រសិទ្ធភាពខ្ពស់ក្នុងការស្វែងរក គ្រប់គ្រង និងឆ្លើយតបទៅហានិភ័យទាំងនោះ មិនថាជាហានិភ័យផ្នែកហិរញ្ញវត្ថុ ហានិភ័យផ្នែកប្រតិបត្តិការ ហានិភ័យផ្នែកនយោបាយ និងហានិភ័យពីបរិយាកាសខាងក្រៅនោះទេ។



# រចនាសម្ព័ន្ធ ហ្វីស ហ្វាយនែន



# អំពីផលិតផល

បើគិតត្រឹមថ្ងៃទី៣១ខែធ្នូឆ្នាំ២០១៦ យើងមានកម្ចីសកម្មចំនួន ២,១៧៦ នៅលើទីផ្សារ ជាមួយផលប័ត្រឥណទានចំនួន ១៩.៧ លានដុល្លារ ។ បច្ចុប្បន្ន យើងមានផលិតផល ៤ ប្រភេទដូចខាងក្រោម៖

## កម្ចីទិញផ្ទះ

កម្ចីទិញផ្ទះរបស់ ហ្វីស ហ្វាយនែន បានអនុញ្ញាតិឲ្យក្រុមគ្រួសារដែលមានចំណូលទាប និងមធ្យម មានផ្ទះទីមួយជាកម្មសិទ្ធិផ្ទាល់ខ្លួន ។ យើងផ្តល់លទ្ធភាពឲ្យអតិថិជនខ្ចីបានរហូតដល់ ៨៥% នៃតម្លៃផ្ទះ ក្នុងរយៈពេល១៥ឆ្នាំ ជាមួយអត្រាការប្រាក់ដែលមានលក្ខណៈប្រកួតប្រជែង ហើយអនុញ្ញាតិឲ្យអតិថិជនរួមគ្នាខ្ចីបានដល់ទៅ ៣នាក់។

កម្ចីទិញផ្ទះសរុបមានចំនួន ៦១៥ ។ កម្ចីនេះមានចំណែកប្រមាណ ៤៤.៦% នៃផលប័ត្រឥណទានសរុប ។




## កម្ចីសាងសង់ ជួសជុលផ្ទះ

កម្ចីសាងសង់ផ្ទះ គឺជាផលិតផលសំខាន់មួយទៀតរបស់យើង ដែលអាចផ្តល់ដំណោះស្រាយផ្នែកហិរញ្ញវត្ថុរយៈពេលវែងសម្រាប់អ្នកមានបំណងសាងសង់ផ្ទះថ្មីលើផ្ទៃដីដែលមានស្រាប់ ឬជួសជុលផ្ទះដែលមានស្រាប់។

ផលិតផលនេះមានលក្ខណៈពិសេស ដោយការបង់សងមានរយៈកាលដល់ទៅ ១៥ឆ្នាំ និងមានទំហំកម្ចីដល់ទៅ ១00% នៃតម្លៃសាងសង់សរុប ។ ផលិតផលនេះមានចំនួន ៩៦២ ដែលស្មើនឹង ៣៧.១% នៃផលប័ត្រឥណទានសរុប។




## កម្ចីទិញដីលំនៅដ្ឋាន

កម្ចីទិញដីលំនៅដ្ឋាន ជាផលិតផលសំខាន់មួយ ដែលមានរយៈពេលវែងសម្រាប់អ្នកមានបំណងទិញដីទុកសាងសង់លំនៅដ្ឋាន

ជាមួយ រយៈពេលវែងរហូតដល់ ១៥ឆ្នាំ និងអាចខ្ចីបានរហូតដល់ ៦៥%នៃតម្លៃសរុប ផលិតផលនេះមានចំនួនសរុប ៣១ ដែលស្មើនឹង ១.១% នៃផលបត្រឥណទានសរុប ។




## កម្ចីអចលនទ្រព្យធានា

កម្ចីអចលនទ្រព្យធានា ត្រូវបានបន្ថែមលើផលិតផលផ្ទះសម្បែងដែលមានស្រាប់ ដើម្បីជួយអតិថិជនរបស់ ហ្វីស ហ្វាយនែន ក្នុងការទិញសម្ភារៈប្រើប្រាស់ ក៏ដូចជាបង្កើតឬពង្រីកអាជីវកម្មរបស់ពួកគេ ។ ប្រាក់កម្ចីនេះអនុញ្ញាតិឲ្យអតិថិជនរបស់យើង អាចប្រើប្រាស់អចលនទ្រព្យរបស់ពួកគាត់ ក្នុងការចាប់យកឱកាសផ្នែកហិរញ្ញវត្ថុផ្សេងៗទៀត។

រយៈពេលបង់សងរបស់កម្ចីនេះគឺរហូតដល់ ១០ ឆ្នាំ ដែលគិតមកទល់បច្ចុប្បន្ន កម្ចីនេះមានចំនួន ៥៤៨ ស្មើនឹង ១៧% នៃផលប័ត្រឥណទានសរុបរបស់យើង ។









លោក ប៊ុនធឿន និងគ្រួសារ ថតជុំគ្នានៅខាងមុខផ្ទះរបស់គាត់

កាលពីឆ្នាំ២០០៣ លោក អ៊ុក ប៊ុនធឿន និងគ្រួសារបានផ្លាស់ប្តូរទីលំនៅពី ស្រុក ត្រាំខ្នា ខេត្តតាកែវ មកកាន់រាជធានីភ្នំពេញដើម្បីស្វែងរកជីវិតប្រសើរជាងមុន។ ពួកគាត់បានជួលបន្ទប់តូចមួយនៅក្នុងក្រុងភ្នំពេញ។ ដើមឡើយបន្ទប់តូចមួយដែលពួកគាត់បានជួលនោះមានលក្ខណៈសមរម្យអាចរស់នៅបាន តែវាបានក្លាយជាបន្ទប់ដ៏តូចចង្អៀតមួយនៅពេលដែលពួកគាត់មានកូនប្រុស២នាក់ ហើយក្រោយមកបងស្រីរបស់ លោក ប៊ុនធឿន បានមករស់នៅជាមួយដែរ។ បន្ទប់នោះពិតជាតូចណាស់សម្រាប់សមាជិក៥នាក់។

លោក ប៊ុនធឿន ព្រមទាំងភរិយានិងបងស្រីធ្វើការនៅរោងចក្រ ភ្លូចថៃមកម្ពុជា។ គាត់ធ្វើការក្នុងការិយាល័យបោះពុម្ព ចំណែកឯប្រពន្ធនិងបងស្រីជាអ្នកកាត់ដេរសំលៀកបំពាក់។ ចំណូលសរុបរបស់ពួកគាត់បាន១,000ដុល្លារក្នុងមួយខែ។ ពួកគាត់បានឮពី ហ្វីស ហ្វាយនែន តាមរយៈការផ្សព្វផ្សាយ ហើយក្រោយមកក៏បានក្លាយជាអតិថិជនរបស់ ហ្វីស ហ្វាយនែន ដោយបានយកកម្ចីរយៈពេល១៣៦ខែ ដើម្បីទិញផ្ទះដែលមានទំហំ ៤.៥ម គុណ ១០ម នៅភូមិត្រពាំងក្រសាំង សង្កាត់ ត្រពាំងក្រសាំង ខណ្ឌ ពោធិ៍សែនជ័យ រាជធានី ភ្នំពេញ កាលពីខែធ្នូ ឆ្នាំ ២០១២។ កន្លងក្រោយមកពួកគាត់ក៏បានយកកម្ចីជួសជុលផ្ទះរយៈពេល ៨៦ខែបន្ថែមដើម្បីជួសជុលនិងសាងសង់ផ្ទះ២ជាន់។ កម្ចីសរុបទាំងមុននិងក្រោយមានទឹកប្រាក់ ១១,៤00 ដុល្លារ។

ចាប់ពីពេលនោះមក ផ្ទះរបស់គាត់បានកើនឡើងតម្លៃ ពី ១៤,0៨0ដុល្លារ ដល់ ៣0,៦00 ដុល្លារ។ ពួកគាត់ទាំងអស់គ្នាមានក្តីសោមន្សរីករាយណាស់ដែលមានឱកាសទិញ និងអភិវឌ្ឍន៍ផ្ទះផ្ទាល់ខ្លួន ដែលប្រសើរជាងចំណាយប្រាក់លើថ្លៃឈ្នួលបន្ទប់។ រីតតែមានភ័ព្វសំណាងជាងនេះទៅទៀត លោក ប៊ុនធឿនបានឈ្នះម៉ូតូ ហុងដា ស៊េរី ឆ្នាំ២០១៦ មួយគ្រឿង ពីកម្មវិធីលើកទឹកចិត្តអតិថិជនរបស់ ហ្វីស ហ្វាយនែន នាចុងឆ្នាំ២០១៦។

លោក ប៊ុនធឿន និងភរិយាមានក្តីសប្បាយរីករាយណាស់ដែលបានឃើញ កូនប្រុសទាំងពីរ អាយុ ១០ឆ្នាំ និង អាយុ ៥ឆ្នាំ អាចរស់នៅ និងរីកចម្រើននៅក្នុងផ្ទះដែលមានសុវត្ថិភាព និងសុខដុម ហើយធំល្មមសម្រាប់ពួកគាត់ទាំងអស់គ្នាសម្រាប់រស់នៅ។



ផ្ទះល្វែង២ជាន់របស់លោក ប៊ុនធឿន

# ព្រឹត្តិការណ៍សំខាន់ៗប្រចាំឆ្នាំ ២០១៦



## ការរួមចំណែកក្នុងសហគមន៍

យើងទាំងអស់គ្នារស់នៅក្រោមដំបូលមេឃ និងលើភពផែនដីតែមួយជាមួយគ្នា អាស្រ័យដោយការយល់ឃើញបែបនេះ នាថ្ងៃទី១០ ខែ ធ្នូ ឆ្នាំ ២០១៦ បុគ្គលិក ហ្វឹស ហ្វាយនែន បានរៀបចំដំណើរកំសាន្ត រយៈពេល ២ថ្ងៃទៅកាន់ខេត្តកំពត ក្នុងគោលបំណងចូលរួមចំណែកកសាងបរិស្ថាន តាមរយៈការដាំដើមកោងកាងនៅស្រុកទឹកឈូ វាជាផ្នែកមួយក្នុងការកសាងបរិស្ថានប្រព័ន្ធអេកូឡូស៊ីនិងភាពប្រសើរសម្រាប់ភាវៈរស់។

## កម្មវិធីថ្លែងអំណរគុណអតិថិជន

ហ្វឹស ហ្វាយនែន បានធ្វើការថ្លែងអំណរគុណដល់អតិថិ-ជនដែលបន្តនៅជាមួយយើងរហូតដល់ផុតកាលបរិច្ឆេទនៃប្រាក់កម្ចី។ ការបង់រហូតដល់ចប់ប្រាក់កម្ចីគឺជាជោគជ័យដ៏ធំមួយរបស់អតិថិជន ហើយ ហ្វឹស ហ្វាយនែន ចង់បង្ហាញនូវការកោតសសើរ និងមោទនភាពដែលយើងជាផ្នែកមួយនៃការសម្រេចនូវដំណើរដ៏វែងឆ្ងាយមួយនេះ តាមរយៈការផ្ញើរសារលិខិតដោយផ្ទាល់ពីអគ្គនាយិការួមជាមួយរង្វាន់លើកទឹកចិត្ត និងបណ្ណបញ្ចុះតម្លៃសម្រាប់អតិថិជនដែលត្រលប់មកប្រើប្រាស់សេវា ហ្វឹស ហ្វាយនែន ម្តងទៀត។









## ការចូលរួមកម្មវិធីថ្នាក់ជាតិ

ក្នុងនាមជាសមាជិករបស់ សមាគមន៍គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកម្ពុជា ពួកយើងបានចូលរួមកម្មវិធីពិព័រណ៍ផលិតផល សេវាកម្មគ្រឹះស្ថានមីក្រូ-ហិរញ្ញវត្ថុ និងសហគ្រាសខ្នាតតូចដែលរៀបចំដោយ ធនាគារជាតិនៃកម្ពុជា នៅកោះពេជ្រ នាខែ មីនា ឆ្នាំ ២០១៦។ វាជាកម្មវិធីថ្នាក់ជាតិមួយ ដែលស្តីអំពីការអភិវឌ្ឍន៍គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅកម្ពុជា។





## ការផ្តល់ការការពារដល់អតិថិជន

យើងជួយអតិថិជនរបស់យើងឲ្យទទួលបានផ្ទះដំបូងជាកម្មសិទ្ធិផ្ទាល់ខ្លួនរបស់ពួកគាត់ ហេតុនេះហើយយើងក៏ចង់ជួយពួកគាត់ក្នុងការថែរក្សា ការពារទ្រព្យមួយនេះដែរ។ នៅឆ្នាំ២០១៦ កន្លងទៅនេះ ហ្វឹស ហ្វាយនែន បានផ្តល់បំពង់ពន្លត់អគ្គីភ័យចំនួនជាង ១០០ទៅដល់អតិថិជនដែលទើបតែមានផ្ទះដំបូងដែលនៅលើបំពង់យើងបានបកប្រែជាភាសាខ្មែរ ព្រមទាំងមានរូបភាពបង្ហាញពីរបៀបប្រើប្រាស់ផងដែរ ហើយយើងសង្ឃឹមថានឹងផ្តល់ជាប្រយោជន៍ក្នុងការផ្តល់នូវសុវត្ថិភាពដល់គ្រួសារនិងទ្រព្យសម្បត្តិរបស់ពួកគេ។ បន្ថែមលើនេះ ហ្វឹស ហ្វាយនែន ក៏បានផ្តល់រង្វាន់ម៉ូតូ និងរង្វាន់ដែលជារបស់ប្រើប្រាស់ក្នុងផ្ទះមួយចំនួនទៀតដល់អតិថិជនដែលមានសំណាង តាមរយៈកម្មវិធីចាប់ឆ្នោតផ្សងសំណាង ។









## ការបង្ហាញស្មារតីជាធ្លុងតែមួយរបស់បុគ្គលិក

ហ្វឺស ហ្វាយនែន នៅតែបន្តការរីកចម្រើនទៅមុខដូច្នេះយើងត្រូវប្រាកដថាក្រុមការងាររបស់យើងគឺជា គ្រួសារមួយដែលរឹងមាំ។ ចំណងជើងសម្រាប់សិក្ខាសាលា ក្នុងឆ្នាំនេះរបស់ពួកយើង គឺ " អ្នកជាចំណែកនៃជោគជ័យរបស់យើង "។ តាមរយៈការពឹងអាស្រ័យ និងការជួយគ្នាទៅវិញទៅមក យើងអាចធ្វើការងារកាន់តែប្រសើរសម្រាប់ខ្លួនឯងនិងសម្រាប់អតិថិជនយើង។ បើទោះបីនៅក្នុងសិក្ខាសាលាមានកម្មវិធីផ្លូវការជាច្រើន ប៉ុន្តែយើងក៏មាន ពេលសប្បាយរីករាយក្នុងគោលបំណងកសាងមិត្តភាពឲ្យកាន់តែរឹងមាំ។









## ការចូលរួមពិធីបុណ្យអុំទូក

ពិធីបុណ្យអុំទូក តែងតែជាពិធីបុណ្យដ៏ឱឡារិកមួយនៅប្រទេសកម្ពុជា។ នៅឆ្នាំនេះ ហ្វឺស ហ្វាយនែន បានសម្រេចចិត្តចូលរួមអបអរពិធីបុណ្យនេះនៅខេត្តបាត់ដំបង។នៅស្តង់ព័ត៌ណ៌ យើងបានចំណាយពេលយ៉ាងច្រើនជាមួយអ្នកទស្សនា ណែនាំពីលក្ខខណ្ឌក្នុងការទទួលប្រាក់កម្ចី ដើម្បីមានផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន ដោយក្នុងនោះយើងក៏មានកម្មវិធីកំសាន្ត ការចាប់ឆ្នោតផ្សងសំណាងក្នុងគោលបំណងទាក់ទាញអ្នកចូលរួមឲ្យបានកុះករ ។



## ពិព័រណ៍ការងារថ្នាក់ជាតិ

ហ្វឺស ហ្វាយនែន តែងតែសម្លឹងមើលបុគ្គលិកថ្មីដែលមានសមត្ថភាព។ ពិព័រ-ណ៍ការងារថ្នាក់ជាតិ ជាកន្លែងមួយដែលយើងអាចស្វែងរកបុគ្គលិក ដែលមានសមត្ថភាព ដែលទើបនឹងបញ្ចប់ការសិក្សា ឬអ្នកដែលកំពុងរកការងារធ្វើ។ យើងរីករាយក្នុងការផ្តល់ឱកាសដល់អ្នកទើបតែបញ្ចប់ការសិក្សាថ្មីឲ្យសម្រេចក្តីស្រម៉ៃរបស់ពួកគេ។



# ហ្វឺស ហ្វាយនែន នៅលើសារព័ត៌មាន












# ចំណាប់អារម្មណ៍របស់បុគ្គលិក



*ចាន់ សូនីកា | បុគ្គលិកស្ម័គ្រចិត្តផ្នែកហិរញ្ញវត្ថុ*

ខ្ញុំឈ្មោះនីកា អាយុ២០ឆ្នាំ ជានិសិត្សឆ្នាំទី៣នៃសាកលវិទ្យាល័យច្បាប់ផ្នែកសេដ្ឋកិច្ចនិងធនាគារ ហើយខ្ញុំក៏ជាបុគ្គលិកស្ម័គ្រចិត្តផ្នែកហិរញ្ញវត្ថុនៅ ហ្វឹស ហ្វាយនែន។ ការសិក្សាដែលរៀនពីគ្រូនៅក្នុងថ្នាក់បានផ្តល់ចំនេះដឹងពីហិរញ្ញវត្ថុយ៉ាងល្អសម្រាប់ខ្ញុំ រីឯការងារនៅ ហ្វឹស ហ្វាយនែន បានផ្តល់ឲ្យខ្ញុំនូវការរីកចម្រើនផ្នែកអាជីពការងារប្រកបដោយវិជ្ជាជីវមួយកម្រិតទៀត ។
ខ្ញុំបានចាប់ផ្តើមការងារជាមួយ ហ្វឹស ហ្វាយនែន ក្នុងខែ តុលា ឆ្នាំ ២០១៦ ដោយខ្ញុំបានដាក់ពាក្យតាមរយៈប្រព័ន្ធអ៊ីនធើណេត។ ធ្វើការនៅទីនេះ គឺជារឿងដែលរំភើបនិងមានអ្វីថ្មីៗជាច្រើនដែលខ្ញុំត្រូវរៀនសូត្របន្ថែម ។ មិត្តរួមការងារ បានជួយឲ្យខ្ញុំផ្លាស់ប្តូរពីនិស្សិត ទៅជាអ្នកធ្វើការដែលប្រកបដោយវិជ្ជាជីវមួយជាក់លាក់។ ។
រឿងដែលគួរឲ្យចាប់អារម្មណ៍នោះគឺថា វប្បធម៌នៅ ហ្វឹស ហ្វាយនែន ពិតជាអស្ចារ្យណាស់។ គ្រប់គ្នាមានភាពរួសរាយរាក់ទាក់ ផ្តល់ភាពកក់ក្តៅ និងចេះជួយគ្នា ហើយខ្ញុំមិនមានអារម្មណ៍ទទួលសម្ពាធពីការងារទេ។ ប្រធានក្រុមរបស់ខ្ញុំជួយជ្រោមជ្រែងខ្ញុំដូចជា បង្រៀនខ្ញុំ ផ្តល់ទំនួលខុសត្រូវដល់ខ្ញុំ កែតម្រូវខ្ញុំដោយរាបសារពេលខ្ញុំជួបបញ្ហា និងផ្តល់សិទ្ធអំណាចដល់ខ្ញុំពេលខ្ញុំអាចទទួលខុសត្រូវដោយខ្លួនឯងបាន។ ខ្ញុំមើលឃើញខ្លួនឯងបានផ្លាស់ប្តូរច្រើន ចាប់តាំងពីបានចូលរួមក្នុង ហ្វឹស ហ្វាយនែន។ ខ្ញុំអាចរៀនប្រាស្រ័យទាក់ទងជាមួយមនុស្សថ្មីៗ អាចបំពេញការងារបានច្រើន សម្របទៅនឹងភាពបត់បែន និងធ្វើការនៅពេលប្រថុចញ៉ូច។
ខ្ញុំពិតជាកោតសរសើរនូវទស្សនវិស័យ និង បេសសកម្មរបស់ ហ្វឹស ហ្វាយនែន ខ្លាំងណាស់ក្នុងការជួយដល់ប្រជាជនខ្មែរដែលមានចំណូលទាប និងមធ្យម៍ឲ្យមានលទ្ធភាពទទួលបានបានលំនៅដ្ឋានដែលជាកម្មសិទ្ធិផ្ទាល់ខ្លួន។ ជាងនេះទៅទៀតខ្ញុំពិតជាសរសើរបុគ្គលិកគ្រប់គ្នានៅហ្វឹស ហ្វាយនែនដែលមានឆន្ទៈក្នុងការរៀនសូត្រ និងអភិវឌ្ឍន៍នូវសមត្ថភាពផ្ទាល់ខ្លួនបន្ថែម ដើម្បីបំពេញតម្រូវការអតិថិជន។ ជាចុងក្រោយ ខ្ញុំសូមអរគុណដល់ ហ្វឹស ហ្វាយនែន ដែលបានផ្តល់ឪកាសដល់ខ្ញុំក្នុងការបម្រើដល់ប្រទេសនិងប្រជាជនរបស់ខ្ញុំ។ ខ្ញុំស្រលាញ់ ហ្វឹស ហ្វាយនែន។



*ចន្ទី វាសនា | មន្ត្រីប្រឹក្សាឥណទាន*

ខ្ញុំបានបម្រើការជាមន្ត្រីប្រឹក្សាឥណទានរបស់ ហ្វឹស ហ្វាយនែន ចាប់តាំងពីខែកក្កដា ឆ្នាំ២០១៥។ ខ្ញុំមកពីខេត្តកំពង់ចាម ហើយខ្ញុំធ្លាប់ធ្វើការនៅស្ថាប័នមីក្រូហិរញ្ញវត្ថុតូចមួយដែលផ្តល់កម្ចីខ្នាតតូចដល់អតិថិជន។ ខ្ញុំបានមកភ្នំពេញ ក្នុងគោលបំណងស្វែងរកបំណិនថ្មីសំរាប់ជីវិតក្នុងអាជីពការងាររបស់ខ្ញុំ។ មូលហេតុដែលខ្ញុំជ្រើសរើសធ្វើការនៅ ហ្វឹស ហ្វាយនែន ពីព្រោះខ្ញុំបានឃើញភាពខុសប្លែកពីគេរបស់ ហ្វឹស ហ្វាយនែន ដែលមានឯកទេសក្នុងការផ្តល់កម្ចីសម្រាប់ប្រជាជនខ្មែរដែលមានចំណូលទាប និងមធ្យមមានផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន។
ខ្ញុំពិតជាចូលចិត្តបរិយាកាសការងារនៅ ហ្វឹស ហ្វាយនែន ជាខ្លាំងពីព្រោះខ្ញុំឃើញថាគ្រប់គ្នា ចាប់តាំងពីឋានៈប្រធានគ្រប់គ្រងជាន់ខ្ពស់រហូតដល់បុគ្គលិកធម្មតា មានភាពរួសរាយរាក់ទាក់ចំពោះគ្នាទៅវិញទៅមកដូចជាគ្រួសារតែមួយ។ ខ្ញុំមិនដែលទទួលអារម្មណ៍សម្ពាធពីឋាននុក្រមនៃតួនាទីឡើយ តែផ្ទុយទៅវិញគឺបានទទួលអារម្មណ៍នៃភាពជាដៃគូការងារដ៏ល្អ។ ខ្ញុំពិតជាមានមោទនភាពចំពោះការងារជាមន្ត្រីប្រឹក្សាឥណទានរបស់ ហ្វឹស ហ្វាយនែន ពីព្រោះខ្ញុំបានជួយប្រឹក្សាដល់ប្រជាជនកម្ពុជា ដែលមិនបានទទួលជំនួយផ្នែកហិរញ្ញវត្ថុដើម្បីមានផ្ទះផ្ទាល់ខ្លួន។ ខ្ញុំពិតជាសប្បាយចិត្តណាស់ដែលបានឃើញអតិថិជនរបស់ខ្ញុំផ្លាស់ប្តូរពីការរស់នៅក្នុងផ្ទះជួលទៅរស់នៅក្នុងផ្ទះផ្ទាល់ខ្លួនរបស់ពួកគាត់។ ខ្ញុំមានមោទនភាពណាស់ដែលការងាររបស់ខ្ញុំអាចរួមចំណែកជួយដល់សហគមន៍របស់ខ្ញុំ។





រូបថតជុំគ្នាក្នុងឱកាសសិក្ខាសាលាប្រចាំឆ្នាំ ២០១៦

# ដៃគូវិនិយោគ

## ភាគទុនិក

www.firstfinance.biz

CLDF Cambodia-Laos Development Fund
www.emergingmarkets.asia

PhillipCapital Your Partner In Finance
www.phillip.com.sg

Norfund
www.norfund.no

INSITOR FUND Seed Capital for Development
www.insitormanagement.com

## អ្នកវិនិយោគប្រាក់កម្ចី

OIKO CREDIT
www.oikocredit.coop

BlueOrchard
www.blueorchard.com

FINNFUND
www.finnfund.fi

symbiotics
www.symbioticsgroup.com

Triple Jump
www.triplejump.eu

incofin
www.incofin.com

bio
www.bio-invest.be

# របាយការណ៍របស់សវនករឯករាជ្យ

(ដកស្រង់ពីរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៦ និងរបាយការណ៍របស់សវនករឯករាជ្យ)

### ជូនចំពោះភាគទុនិកហ្វីស ហ្វាយនែន ភីអិលស៊ី

## មតិសវនកម្ម

យើងខ្ញុំ បានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វីស ហ្វាយនែន ភីអិលស៊ី ហៅកាត់ថា ("ក្រុមហ៊ុន" ឬ "ហ្វីស ហ្វាយនែន") ដែលរួមមានតារាងតុល្យការនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016 របាយការណ៍លទ្ធផល របាយការណ៍ស្តីពីបំរែបម្រួលមូលធន និងរបាយការណ៍លំហូរទឹកប្រាក់ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សំគាល់ដែលរួមមានគោលនយោបាយ គណនេយ្យសំខាន់ៗ ព្រមទាំងព័ត៌មានពន្យល់ផ្សេងៗទៀត ។

ជាមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុជាសារវន្ត បានបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាព ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់របស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ។

## មូលដ្ឋាននៃមតិសវនកម្ម

យើងខ្ញុំបានធ្វើសវនកម្ម ដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា ។ ការទទួលខុសត្រូវរបស់យើងខ្ញុំដែលស្របតាមស្តង់ដារទាំងនោះ ត្រូវបានរៀបរាប់បន្ថែមទៀតនៅក្នុង កថាខ័ណ្ឌស្តីពីការទទួលខុសត្រូវរបស់សវនករ សម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុដែលមាននូវក្នុងរបាយការណ៍របស់យើងខ្ញុំ ។ យើងខ្ញុំ មានភាពឯករាជ្យពីក្រុមហ៊ុន ដោយស្របទៅតាមតម្រូវការក្រមសីលធម៌វិជ្ជាជីវៈ ដែលពាក់ព័ន្ធនឹងសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយយើងខ្ញុំ បានបំពេញនូវទំនួលខុសត្រូវក្រមសីលធម៌វិជ្ជាជីវៈស្របតាមតម្រូវការរបស់ស្តង់ដារ ទាំងនោះ។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងខ្ញុំប្រមូលបានមានលក្ខណៈគ្រប់គ្រាន់ និងសមស្រប សម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ ។

## ព័ត៌មានផ្សេងៗ

អ្នកគ្រប់គ្រង មានភារៈទទួលខុសត្រូវលើព័ត៌មានផ្សេងៗ ។ ព័ត៌មានផ្សេងៗ ដែលបានទទួលត្រឹមកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ គឺរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល និង របាយការណ៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុន ដែលរំពឹងថារួចរាល់បន្ទាប់ពីកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ។

មតិសវនកម្មរបស់យើងខ្ញុំ ទៅលើរបាយការណ៍ហិរញ្ញវត្ថុ មិនបានគ្របដណ្តប់លើព័ត៌មានផ្សេងៗទេឡើយ ហើយយើងខ្ញុំមិនធ្វើការផ្តល់នូវអំណះអំណាងណាមួយទៅលើព័ត៌មាននេះទេ ។

ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺត្រូវអានព័ត៌មានផ្សេងៗ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានភាពមិនស្របគ្នាជាសារវន្តជាមួយរបាយការណ៍ហិរញ្ញវត្ថុ ឬការយល់ដឹងរបស់យើងខ្ញុំនៅក្នុងការធ្វើសវនកម្ម ឬមានបង្ហាញនូវកំហុសឆ្គងជាសារវន្ត ។

ប្រសិនបើការអានព័ត៌មានផ្សេងៗ ដែលបានទទួលមុនកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ អាចឲ្យយើងខ្ញុំសន្និដ្ឋានថា មានកំហុសឆ្គងជាសារវន្តកើតឡើង យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំ ពុំមានអ្វីដែលត្រូវរាយការណ៍ពាក់ព័ន្ធនឹងព័ត៌មានផ្សេងៗនេះទេ ។

## ការទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុរបស់អ្នកគ្រប់គ្រង និងអ្នកទទួលខុសត្រូវលើអភិបាលកិច្ច

អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការរៀបចំ និងការបង្ហាញនូវភាពត្រឹមត្រូវ នៃរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមទៅតាមស្តង់ដារគណនេយ្យកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា ពាក់ព័ន្ធនឹងការរៀបចំ និងការកំណត់បង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ហើយនិងទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលអ្នកគ្រប់គ្រងកំណត់ថាមានភាពចាំបាច់សម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុឲ្យជៀសផុតពីការបង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង ។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការវាយតម្លៃ នូវលទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តរភាពអាជីវកម្មទទួលខុសត្រូវលើការលាតត្រដាងព័ត៌មានប្រសិនបើពាក់ព័ន្ធនូវបញ្ហា ទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជី ផ្អាកដំណើរការក្រុមហ៊ុន ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ ។

អ្នកទទួលខុសត្រូវលើអភិបាលកិច្ច មានភារៈទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ។

## ការទទួលខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលដៅរបស់យើងខ្ញុំ គឺផ្តល់នូវអំណះអំណាងសមហេតុផលថារបាយការណ៍ហិរញ្ញវត្ថុទាំងមូលមិនមានការបង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងផ្តល់នូវរបាយការណ៍របស់សវនករ ដែលរួមបញ្ចូលទាំងមតិសវនកម្មរបស់យើងខ្ញុំ ។ អំណះអំណាងសមហេតុផលគឺជាអំណះអំណាងមានកម្រិតខ្ពស់មួយ ប៉ុន្តែវាមិនអាចធានាថា គ្រប់ពេលនៃការធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា អាចរកឃើញនូវការបង្ហាញខុសជាសារវន្តដែលបានកើតឡើងនោះទេ ។ ការបង្ហាញខុសជាសារវន្តអាចកើតឡើងដោយសារការក្លែងបន្លំ ឬកំហុសឆ្គង ហើយត្រូវបានចាត់ទុកថាជាសារវន្ត នៅពេលដែលការក្លែងបន្លំ ឬកំហុសឆ្គងតែមួយ ឬក៏រួមបញ្ចូលគ្នាមានផលប៉ះពាល់ដល់ការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ដោយយោងលើរបាយការណ៍ហិរញ្ញវត្ថុនេះ ។

ជាផ្នែកមួយនៃការធ្វើសវនកម្ម ដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវការវិនិច្ឆ័យដែលប្រកបទៅដោយវិជ្ជាជីវៈ និងរក្សានូវមជ្ឈធាតុនិយម ក្នុងអំឡុងពេលសវនកម្ម ។ យើងខ្ញុំក៏៖

- ធ្វើការកំណត់ និងវាយតម្លៃនូវហានិភ័យនៃការបង្ហាញខុសជាសារវន្តលើរបាយការណ៍ហិរញ្ញវត្ថុដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងទទួលខុសត្រូវលើការរៀបចំ និងការអនុវត្តនូវនីតិវិធីសវនកម្ម ដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងប្រមូលនូវភស្តុតាងដែលមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ ។ ហានិភ័យដែលមិនអាចរកឃើញនូវការបង្ហាញខុសជាសារវន្តដែលកើតឡើងដោយសារតែការក្លែងបន្លំ មានលក្ខណៈខ្ពស់ជាងការបង្ហាញខុសកើតឡើងពីកំហុសឆ្គង ដោយសារតែការក្លែងបន្លំអាចរួមបញ្ចូលទាំងការឃុបឃិតគ្នា ការលួចបន្លំ ការលុបចោលដោយចេតនា ការបកស្រាយមិនពិត ឬមិនអនុវត្តតាមនីតិវិធីគ្រប់គ្រងផ្ទៃក្នុង ។
- ទទួលបាននូវការយល់ដឹងអំពីការគ្រប់គ្រងផ្ទៃក្នុង ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្មក្នុងគោលបំណងដើម្បីរៀបចំនូវនីតិវិធីសវនកម្ម ដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនក្នុងគោលបំណងដើម្បីបញ្ចេញមតិលើប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុនឡើយ។
- ការវាយតម្លៃលើភាពសមស្រប នៃគោលនយោបាយគណនេយ្យដែលក្រុមហ៊ុនបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យសំខាន់ៗ ព្រមទាំងការលាតត្រដាងព័ត៌មានពាក់ព័ន្ធដែលបានធ្វើឡើងដោយអ្នកគ្រប់គ្រង ។
- ធ្វើការសន្និដ្ឋានលើភាពសមស្រប នៃការប្រើប្រាស់មូលដ្ឋាននិរន្តរភាព នៃគណនេយ្យរបស់អ្នកគ្រប់គ្រង ហើយដោយផ្អែកទៅលើភស្តុតាងសវនកម្ម ដែលទទួលបានធ្វើការសន្និដ្ឋានថាតើភាពមិនច្បាស់លាស់សារវន្តពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចធ្វើឲ្យមានមន្ទិលជាសារវន្តលើលទ្ធភាពរបស់ក្រុមហ៊ុន ដើម្បីបន្តនិរន្តរភាពអាជីវកម្ម ។ ប្រសិនបើយើងខ្ញុំធ្វើការសន្និដ្ឋានថាមានអត្ថិភាពនៃភាពមិនប្រាកដប្រជាជាសារវន្ត យើងខ្ញុំចាំបាច់ត្រូវបញ្ចូលនៅក្នុងរបាយការណ៍របស់យើងខ្ញុំដើម្បីទាញចំណាប់ អារម្មណ៍លើការលាតត្រដាងព័ត៌មានពាក់ព័ន្ធ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងព័ត៌មានមានលក្ខណៈមិនគ្រប់គ្រាន់ យើងខ្ញុំចាំបាច់ត្រូវផ្តល់មតិសវនកម្មដែលមានបញ្ហា ។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកតាមភស្តុតាងសវនកម្មដែលប្រមូលបានត្រឹមកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មរបស់យើងខ្ញុំ ។ យ៉ាងណាក៏ដោយព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគតអាចធ្វើឲ្យក្រុមហ៊ុនបញ្ឈប់និរន្តរភាពនៃអាជីវកម្ម ។
- វាយតម្លៃលើការបង្ហាញនៃទម្រង់ និងខ្លឹមសារនៃរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ដែលរួមបញ្ចូលទាំងការលាតត្រដាងព័ត៌មាន និងវាយតម្លៃថាតើរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ពាក់ព័ន្ធក្នុងអត្ថន័យ ដែលអាចសម្រេចបាននូវការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ ។

យើងខ្ញុំ ផ្តល់ព័ត៌មានជូនអ្នកទទួលខុសត្រូវលើអភិបាលកិច្ចស្តីពីបញ្ហាផ្សេងទៀត វិសាលភាព និងពេលវេលា ដែលបានគ្រោងទុកសម្រាប់ការធ្វើសវនកម្ម និងការរកឃើញបញ្ហាជាសារវន្តផ្សេងទៀត ដែលមានរួមបញ្ចូលទាំងចំនុចខ្វះខាតនៃការគ្រប់គ្រងផ្ទៃក្នុង ដែលបានរកឃើញក្នុងអំឡុងពេលធ្វើសវនកម្ម ។




ថ្ងៃទី ៣១ ខែមីនា ឆ្នាំ ២០១៧

# តារាងតុល្យការ

( ដកស្រង់ពីរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៦ និងរបាយការណ៍របស់សវនករឯករាជ្យ )

| | 2016 | | 2015 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ទ្រព្យសកម្ម | | | | |
| សាច់ប្រាក់ក្នុងដៃ | 3,689 | 14,892 | 2,815 | 11,401 |
| ប្រាក់បញ្ញើនៅធនាគារ | 7,171,167 | 28,950,001 | 1,685,566 | 6,826,542 |
| ប្រាក់បញ្ញើតម្កល់តាមច្បាប់ | 180,102 | 727,072 | 180,102 | 729,413 |
| ឥណទានផ្តល់ដល់អតិថិជន | 19,141,733 | 77,275,176 | 21,135,479 | 85,598,690 |
| ទ្រព្យសកម្មផ្សេងៗ | 496,431 | 2,004,092 | 320,888 | 1,299,596 |
| ទ្រព្យ និងបរិក្ខារ | 149,531 | 603,657 | 111,679 | 452,300 |
| ទ្រព្យសកម្មអរូបី | - | - | 32,973 | 133,541 |
| ទ្រព្យសកម្មពន្ធពន្យារសុទ្ធ | 114,858 | 463,682 | 55,089 | 223,110 |
| **សរុបទ្រព្យសកម្ម** | **27,257,511** | **110,038,572** | **23,524,591** | **95,274,593** |
| បំណុល និងមូលធន | | | | |
| បំណុល | | | | |
| ប្រាក់កម្ចី | 19,756,303 | 79,756,195 | 16,438,371 | 66,575,403 |
| បំណុលផ្សេងៗ | 813,064 | 3,282,339 | 711,086 | 2,879,898 |
| សំវិធានធនសម្រាប់ពន្ធ លើប្រាក់ចំណេញ | 146,847 | 592,822 | 202,071 | 818,388 |
| **សរុបបំណុល** | **20,716,214** | **83,631,356** | **17,351,528** | **70,273,689** |
| មូលធន | | | | |
| ដើមទុន | 2,926,955 | 11,816,117 | 2,289,370 | 9,271,949 |
| ដើមទុនបន្ថែម និង បុព្វលាភភាគហ៊ុន | 1,554,560 | 6,275,759 | 2,192,145 | 8,878,186 |
| ប្រាក់ចំណេញរក្សាទុក | 2,059,782 | 8,315,340 | 1,691,548 | 6,850,769 |
| **សរុបមូលធន** | **6,541,297** | **26,407,216** | **6,173,063** | **25,000,904** |
| **សរុបបំណុលនិងមូលធន** | **27,257,511** | **110,038,572** | **23,524,591** | **95,274,593** |

# របាយការណ៍លទ្ធផល

( ដកស្រង់ពីរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៦ និងរបាយការណ៍របស់សវនករឯករាជ្យ )

| | 2016 | | 2015 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណូលពីការប្រាក់ | 3,913,269 | 15,797,867 | 3,362,950 | 13,619,948 |
| ចំណាយលើការប្រាក់ | ( 1,660,495 ) | ( 6,703,418 ) | ( 1,364,024 ) | ( 5,524,297 ) |
| **ចំណូលពីការប្រាក់សុទ្ធ** | **2,252,774** | **9,094,449** | **1,998,926** | **8,095,651** |
| ចំណូលពីប្រតិបត្តិការផ្សេងៗ | 287,392 | 1,160,201 | 428,845 | 1,736,822 |
| **ចំណូលពីប្រតិបត្តិការ** | **2,540,166** | **10,254,650** | **2,427,771** | **9,832,473** |
| សំវិធានធនលើឥណទាន អាក្រក់ និងជាប់សង្ស័យ | ( 563,491 ) | ( 2,274,813 ) | ( 400,411 ) | ( 1,621,665 ) |
| ចំណាយទូទៅ និងរដ្ឋបាល | ( 1,481,976 ) | ( 5,982,737 ) | ( 1,052,113 ) | ( 4,261,058 ) |
| **ប្រាក់ចំណេញមុនដកពន្ធ** | **494,699** | **1,997,100** | **975,247** | **3,949,750** |
| ពន្ធលើប្រាក់ចំណេញ | ( 126,465 ) | ( 510,539 ) | ( 181,483 ) | ( 735,007 ) |
| **ប្រាក់ចំណេញសុទ្ធ សម្រាប់ការិយបរិច្ឆេទ** | **368,234** | **1,486,561** | **793,764** | **3,214,743** |

# របាយការណ៍ស្តីពីបម្រែបម្រួលមូលធន

(ដកស្រង់ពីរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៦ និងរបាយការណ៍របស់សវនករឯករាជ្យ)

| | ដើមទុន<br>ដុល្លារអាមេរិក | ដើមទុនបន្ថែមនិង<br>បុព្វលាភភាគហ៊ុន<br>ដុល្លារអាមេរិក | ប្រាក់ចំណេញ<br>រក្សាទុក<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក |
|---|---|---|---|---|
| នាថ្ងៃទី 1 ខែ មករា ឆ្នាំ 2015 | 2,289,370 | 950,002 | 897,784 | 4,137,156 |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | 793,764 | 793,764 |
| ផ្ទេរពីប្រាក់កម្ចី | - | 1,242,143 | - | 1,242,143 |
| នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2015 | 2,289,370 | 2,192,145 | 1,691,548 | 6,173,063 |
| (សមតុល្យជាពាន់រៀល) | 9,271,949 | 8,878,186 | 6,850,769 | 25,000,904 |
| នាថ្ងៃទី 1 ខែ មករា ឆ្នាំ 2016 | 2,289,370 | 2,192,145 | 1,691,548 | 6,173,063 |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | 368,234 | 368,234 |
| ផ្ទេរពីប្រាក់កម្ចី | 637,585 | (637,585) | | -- |
| នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2016 | 2,926,955 | 1,554,560 | 2,059,782 | 6,541,297 |
| (ស្មើនឹងពាន់រៀល) | 11,816,117 | 6,275,759 | 8,315,340 | 26,407,216 |

# របាយការណ៍លំហូរទឹកប្រាក់

(ដកស្រង់ពីរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៦ និងរបាយការណ៍របស់សវនករឯករាជ្យ)

| | 2016 | | 2015 | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **លំហូរទឹកប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | |
| សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពប្រតិបត្តិការ | 2,186,424 | 8,826,593 | (4,871,478) | (19,729,486) |
| **លំហូរទឹកប្រាក់ពីសកម្មភាពវិនិយោគ** | | | | |
| ការទិញទ្រព្យ និងបរិក្ខារ | (111,676) | (450,836) | (93,358) | (378,100) |
| ការទិញទ្រព្យសកម្មអរូបី | - | - | (23,662) | (95,831) |
| សាច់ប្រាក់ទទួលបានពីការលក់ទ្រព្យ និងបរិក្ខារ | 52 | 210 | 8,200 | 33,210 |
| ប្រាក់បញ្ញើមានកាលកំណត់ | (1,000,000) | (4,037,000) | - | - |
| សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុងសកម្មភាពវិនិយោគ | (1,111,624) | (4,487,626) | (108,820) | (440,721) |
| **លំហូរទឹកប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | |
| សាច់ប្រាក់ទទួលបានពីប្រាក់កម្ចី | 5,000,000 | 20,185,000 | 3,759,387 | 15,225,517 |
| ការទូទាត់សងប្រាក់កម្ចី | (1,682,068) | (6,790,509) | (786,521) | (3,185,410) |
| សាច់ប្រាក់សុទ្ធទទួលបានពីសកម្មភាពហិរញ្ញប្បទាន | 3,317,932 | 13,394,491 | 2,972,866 | 12,040,107 |
| **ការកើនឡើង/(ថយចុះ) នូវសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | **4,392,732** | **17,733,459** | **(2,007,432)** | **(8,130,100)** |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាថ្ងៃទី 1 ខែ មករា** | **1,688,381** | **6,837,943** | **3,695,813** | **15,060,438** |
| **ភាពលំអៀងនៃការប្តូររូបិយប័ណ្ណ** | **-** | **(21,949)** | **-** | **(92,395)** |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាថ្ងៃទី 31 ខែ ធ្នូ** | **6,081,113** | **24,549,453** | **1,688,381** | **6,837,943** |

# ក្រុមប្រឹក្សាភិបាលនិងថ្នាក់ដឹកនាំ







## LEE-ANNE PITCAITHLY
### ប្រធានក្រុមប្រឹក្សាភិបាល

លោកស្រី Lee-Anne Pitcaithly បានចូលរួមជាមួយ ហ្វីស ហ្វាយនែន ក្នុងឆ្នាំ២០១៤ ជាប្រធានក្រុមប្រឹក្សាភិបាល ជាមួយបទពិសោធន៍ជាលក្ខណៈអន្តរជាតិ រយៈពេល៨ឆ្នាំ ក្នុងវិស័យសេវាហិរញ្ញវត្ថុចល័តដើម្បីបម្រើដល់ជនក្រីក្រ ។ រួមជាមួយជំនាញខាងផ្នែកគ្រប់គ្រងពាណិជ្ជកម្ម និងបទពិសោធន៍ ក្នុងធនាគារពាណិជ្ជ និងក្រុមហ៊ុនផ្នែកទូរគមនាគមន៍ លោកស្រី Lee-Anne បាននាំមកនូវចំណេះនិងជំនាញជាច្រើនទៅក្នុងមុខតំណែងរបស់គាត់។ លោកស្រី Lee-Anne ធ្លាប់កាន់តួនាទីជាច្រើនក្នុងតំណែងជាថ្នាក់ដឹកនាំរបស់ក្រុមហ៊ុនវីង (កម្ពុជា) និង Grameen Foundation (យូហ្កាន់ដា)។ ដោយមានទីលំនៅក្នុងប្រទេសកម្ពុជា លោកស្រី Lee-Anne នូវតែបន្តការងារជាអ្នកប្រឹក្សាយោបល់ជាលក្ខណៈអន្តរជាតិសម្រាប់សេវាហិរញ្ញវត្ថុឌីជីថល។

## TALMAGE PAYNE
### អភិបាល
#### តំណាងម្ចាស់ភាគហ៊ុន ហ្វីស ហូម ទីអិលស៊ី

លោក Talmage Payne ជាសហគ្រិន និងអ្នកមានគំនិតច្នៃប្រឌិតមួយរូប ហើយសព្វថ្ងៃជាប្រធាននៃអង្គការសេចក្តីសង្ឃឹមពិភពលោកអន្តរជាតិប្រចាំនៅកម្ពុជា។ គាត់គឺជាស្ថាបនិក ហ្វីស ហ្វាយនែន និងអាជីវកម្មសង្គមជាច្រើនទៀត។ គាត់បានចំណាយពេលស្ទើរមួយជីវិតរបស់គាត់រស់ នៅទ្វីបអាស៊ី ដើម្បីធ្វើការទាំងក្នុងស្ថាប័នរកប្រាក់ចំណេញ និងស្ថាប័នមិនរកប្រាក់ចំណេញ ដែលផ្តល់ភាពវិជ្ជមានដល់សង្គម ។ គាត់ធ្លាប់ជានាយកប្រតិបត្តិនៃអង្គការ Hagar International (ការការពារ និង ការធ្វើឲ្យប្រសើរឡើងដល់អ្នកដែលរួចផុតពីការជួញដូរមនុស្ស) និងបានជួយបង្កើត Hagar ចំនួន ៩ប្រទេសដោយប្រើម៉ូដែល មានទាំងការរកប្រាក់ចំណេញ និងមិនរកប្រាក់ចំណេញ ។ លោកធ្លាប់ជានាយកអង្គការទស្សនៈពិភពលោកកម្ពុជា និងជាប្រធានស្ថាបនិក វីសិនហ្វាន់កម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់ការងារមនុស្សធម៌របស់លោកជាច្រើនលើកតាមរយៈការបំពាក់មេដាយ ថ្នាក់មនុស្សជាតិពីរដង និងងារសហមេត្រី។ លោក បានសិក្សាមុខវិជ្ជាអភិវឌ្ឍន៍សេដ្ឋកិច្ចនៅសាកលវិទ្យាល័យ Wheaton College។

## NICHOLAS LAZOS
### អភិបាល
#### តំណាងម្ចាស់ភាគហ៊ុន Insitor Fund

លោក Nicholas Lazos គឺជាសហស្ថានិក និងជានាយកនៃក្រុមហ៊ុន Insitor Impact Asia Fund លោក Nicholas បានធ្វើការនៅភាគខាងត្បូង និង អាស៊ីអាគ្នេយ៍អស់រយៈពេល៩ឆ្នាំ ព្រមទាំងបានជួយសហគ្រាសសង្គម ក្នុងដំណាក់កាលចាប់ផ្តើម ។ លោក Nicholas ទទួលខុសត្រូវលើវិនិយោគទុនធំៗ និងមានតួនាទីជាអភិបាលនៅក្នុងក្រុមហ៊ុនដែល Insitor បានវិនិយោគ។ មុននឹងចូលបម្រើការនៅ Insitor លោក Nicholas គឺជាប្រធានចាត់ការទូទៅ របស់ក្រុមហ៊ុនដែលផ្តល់ដំណោះស្រាយ ខាងគេហដ្ឋានដល់អ្នកដែលមានចំណូលទាប មុនគេបង្អស់នៅកម្ពុជា។ លោកបានរៀបចំចាត់ចែងតាំងពីដំបូង និងអភិវឌ្ឍរហូតមានប្រតិបត្តិការពេញលេញ។ គាត់ទទួលបានសញ្ញាប័ត្រពីរគឺ ផ្នែកគណិតវិទ្យានៅក្នុងកម្មវិធីវិទ្យាសាស្ត្រសង្គមពីសាកលវិទ្យាល័យ Northwestern University ។

## ក្រុមប្រឹក្សាភិបាល







## ONG TEONG HOON
### អភិបាល
#### តំណាងម្ចាស់ភាគហ៊ុន Phillip Capital

លោក Ong Teong Hoon មានបទពិសោធន៍ជាង ៣០ឆ្នាំ ក្នុងវិស័យធនាគារនៅអាស៊ី និងបទពិសោធន៍ប៉ុន្មានឆ្នាំចុងក្រោយក្នុងវិស័យមីក្រូ-ហិរញ្ញវត្ថុ។ លោក Teong Hoon គឺជានាយកប្រតិបត្តិជាន់ខ្ពស់ប្រចាំក្រុមហ៊ុន Phillip Capital ដែលជាក្រុមហ៊ុននាំមុខមួយនៅក្នុងអាស៊ី ហើយបច្ចុប្បន្នជាអភិបាលនៅធនាគារ Phillip ក្នុងប្រទេសកម្ពុជា និងជាអភិបាលក្នុងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្រេឌីត នៅកម្ពុជា ។
លោកជាប្រធានក្រុមប្រឹក្សាភិបាលសាលា Methodist ក្នុងប្រទេសកម្ពុជា និងមានតួនាទីជាថ្នាក់ដឹកនាំកំពូលនៃកម្មវិធី Youth and Detention Rehabilitation Program ។ លោក Teong Hoon ក៏ជាសមាជិកស្ថាបនិកក្រុមប្រឹក្សាភិបាលរបស់ហ្វីស ហ្វាយនែន និងបានធ្វើដំណើរជាមួយយើងឆ្លងកាត់ទាំងភាពលំបាក ការរីកចម្រើនខ្លាំង និងជ័យជំនះ។ គាត់ក៏ជាសមាជិកនៃវិទ្យាស្ថានធនាគារក្នុងទីក្រុងឡុងដ៍ផងដែរ (The Chartered Institute of Bankers in London) ។

## FAY CHETNA
### អភិបាល
#### តំណាងម្ចាស់ភាគហ៊ុន Norfund

អ្នកស្រី Fay Chetna ជានាយិកាផ្នែកវិនិយោគ និងជាប្រធាននៃ Norfund ប្រចាំនៅអាស៊ី ។ អ្នកស្រីមានតួនាទីក្នុងការគ្រប់គ្រង និងដឹកនាំផលបត្ររបស់ Norfund នៅអាស៊ី។ មុនមកកាន់ Norfund អ្នកស្រីបានបម្រើការងារនៅសហប្រតិបត្តិការហិរញ្ញវត្ថុអន្តរជាតិនិងធនាគាពិភពលោក។ អ្នកស្រីក៏មានបទពិសោធន៍ក្នុងវិស័យអភិវឌ្ឍន៍ហិរញ្ញវត្ថុតាមបណ្តាប្រទេសនៅតំបន់អាស៊ីអាគ្នេយ៍ អាព្រិច អាមេរិកឡាទីន និងអឺរ៉ុបខាងកើត។ អ្នកស្រីបានបញ្ចប់ការសិក្សាពីសាកវិទ្យាល័យ Johns Hopkins ផ្នែកសិក្សាអន្តរជាតិជាន់ខ្ពស់។

## BRAD JONES
### សមាជិកក្រុមប្រឹក្សាឯករាជ្យ

លោក Brad Jones ធ្លាប់ជាអ្នកគ្រប់គ្រងជាន់ខ្ពស់ និង ជានាយកប្រតិបត្តិក្នុងវិស័យធនាគារ និងការទូទាត់នៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក មជ្ឈឹមបូព៌ានិងប្រទេសអូស្ត្រលី។ បទពិសោធន៍របស់លោករួមមានការចាប់ផ្តើមអាជីវកម្មក្នុងទីផ្សារកំពុងអភិវឌ្ឍន៍ដែលមានការលំបាក រហូតដល់ការគ្រប់គ្រងប្រតិបត្តិការក្នុងធនាគារអន្តរជាតិ។ បច្ចុប្បន្ន លោក Brad គឺជានាយកក្រុមហ៊ុន Wave Money ក្នុងការផ្តល់សេវាផ្ទេរប្រាក់ចល័ត ដែលក្រុមហ៊ុននេះបានបណ្តាក់ទុន នៅក្នុងប្រទេសភូមា រវាងក្រុមហ៊ុន Telenor នឹងធនាគារ Yoma ។ កន្លងមក លោកគឺជាស្ថាបនិកនាយកគ្រប់គ្រងរបស់ក្រុមហ៊ុន វីង និងជាថ្នាក់ដឹកនាំជាន់ខ្ពស់ ក្នុងការច្នៃប្រឌិតទៅលើប្រព័ន្ធទូរស័ព្ទចល័ត សម្រាប់ផលិតផល Visa ។ បន្ថែមលើបទពិសោធន៍ក្រុមហ៊ុនដ៏ទូលំទូលាយ គាត់ធ្លាប់ផ្តល់ការប្រឹក្សាដល់ World Bank Group, Grameen Foundation, និង DFID សម្រាប់ផ្នែកសេវាហិរញ្ញវត្ថុ ឌីជីថល។ លោកទទួលបានបរិញ្ញាបត្រពាណិជ្ជកម្មពីសាកលវិទ្យាល័យ Griffith និងសញ្ញាបត្រអនុបណ្ឌិតពីសាកលវិទ្យាល័យ University of Queensland ។

# ក្រុមប្រឹក្សាភិបាល



## លោក វិចិត្រ វណ្ណារដ្ឋ
### អភិបាល
#### តំណាងម្ចាស់ភាគហ៊ុន CLDF

លោក វិចិត្រ វណ្ណារដ្ឋ បានចូលរួមជាអភិបាលតំណាងម្ចាស់ភាគហ៊ុនរបស់ ហ្វីស ហ្វាយនែន នាឆ្នាំ២០១៦។ លោកបានបម្រើការងារក្នុងវិស័យស្ថាប័នហិរញ្ញវត្ថុជាង ១០ឆ្នាំដោយមានបទពិសោធន៍ក្នុងវិស័យធនាគារអន្តរជាតិ និងបទពិសោធន៍វិនិយោគពីសហរដ្ឋអាមេរិក អឺរ៉ុប និងកម្ពុជា។ សព្វថ្ងៃនេះលោក វណ្ណារដ្ឋ ជាប្រធានគ្រប់គ្រងការវិនិយោគនៃ Emerging Markets Investment Advisors (EMIA) ដែលជាក្រុមហ៊ុនឯកជនរបស់សឹង្ហបុរី ផ្តល់សេវាប្រឹក្សាយោបល់វិនិយោគ។ មុនមកកាន់ទីនេះ គាត់ធ្លាប់មានតួនាទីជាច្រើនដូចជា នាយកប្រតិបត្តិប្រធានប្រឹក្សាសហប្រតិបត្តិការហិរញ្ញវត្ថុនៅ Cana Securities, the investment banking arm of Canadia Investment Holding Plc.

លោក វណ្ណារដ្ឋ បានបញ្ចប់អនុបណ្ឌិតផ្នែកគ្រប់គ្រងនៅសាកលវិទ្យាល័យ Harvard និងបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកធនាគារ និងហិរញ្ញវត្ថុ ពីសាលាពាណិជ្ជសាស្ត្រអឺរ៉ុប ESCP ។ លោកក៏ជាសមាជិកនៃ CPA របស់ អូស្ត្រាលី ផងដែរ។



## PAUL FREER
### សមាជិកក្រុមប្រឹក្សាឯករាជ្យ

លោក Paul Freer មានបទពិសោធន៍ក្នុងតំណែងជាន់ខ្ពស់ជាង ២០ឆ្នាំជាមួយធនាគារអន្តរជាតិ និងមានប្រវត្តិទទួលបានជោគជ័យក្នុងការគ្រប់គ្រងគំរោង ការអប់រំ ជាមួយវិស័យអង្គការមិនរកប្រាក់ចំណេញក្នុងប្រទេសកម្ពុជា ។

លោក Paul បានចាប់ផ្តើមអាជីពធនាគារដំបូង ក្នុងប្រទេសអង់គ្លេស មុនពេលចំណាយពេល១៥ឆ្នាំទៀតធ្វើការក្នុងប្រទេសកម្ពុជា និងប្រទេសឡាវក្នុងមុខដំណែងអ្នកគ្រប់គ្រងជាន់ខ្ពស់ ក្នុងអង្គការទាំងរកប្រាក់ចំណេញ និងមិនរកប្រាក់ចំណេញ ។ លោក Paul ធ្លាប់ជានាយកប្រតិបត្តិធនាគារ Standard Charted Bank ក្នុងប្រទេសកម្ពុជា នាយកគ្រប់គ្រងធនាគារ Phongsavanh Bank ក្នុងប្រទេសឡាវ និងជានាយកផ្នែក Retail Banking នៃធនាគារ ANZ Royal Bank (Cambodia)។ គាត់ក៏បានរួមចំណែកក្នុងការបង្កើតធនាគារ MARUHAN Japan BANK ក្នុងប្រទេសកម្ពុជាដោយគាត់បានបំរើការជាអគ្គនាយករង និងជាអ្នកចាត់ការទូទៅ។

លោក Paul គឺជាសមាជិកគណៈកម្មាធិការផ្នែកហិរញ្ញវត្ថុ និងសម្ភារៈបរិក្ខាររបស់សាលា International School of Phnom Penh និងជាអ្នកប្រឹក្សាឯករាជ្យលើវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុជាមួយធនាគារពិភពលោក ក៏ដូចជាអង្គការដ៏ទៃទៀត។

លោក Paul ទទួលបានសញ្ញាបត្រអនុបណ្ឌិតគ្រប់គ្រងពាណិជ្ជកម្មពីសាកលវិទ្យាល័យ Southampton Business School របស់ប្រទេសអង់គ្លេស។



## JOSHUA MORRIS
### អ្នកអង្កេត
#### តំណាងម្ចាស់ភាគហ៊ុន CLDF

លោក Joshua Morris ជាដៃគូរស្ថាបនិកនិងជានាយកគ្រប់គ្រងនៃ Emerging Markets Investments (EMI) ជាអាជីវកម្មផ្តល់ប្រឹក្សាវិនិយោគដែលមានមូលដ្ឋាននៅប្រទេសកម្ពុជា និងគ្រប់គ្រង Cambodia-Laos Development Fund ។ មុនពេលបង្កើត EMI លោក Joshua បានចូលរួមយ៉ាងសកម្ម ក្នុងការអភិវឌ្ឍន៍វិស័យឯកជន និងផ្តល់ប្រឹក្សាអាជីវកម្មនៅក្នុងអាស៊ីអាគ្នេយ៍ តាមរយៈតួនាទីរបស់លោកជាសហស្ថាបនិកក្រុមហ៊ុន Emerging Markets Consulting ដែលជាក្រុមហ៊ុនប្អូនរបស់ក្រុមហ៊ុន EMI ។

មុនពេលប្តូរមករស់នៅកម្ពុជាក្នុងឆ្នាំ ២០០៤ លោក Joshua មានការងារជាអ្នកគ្រប់គ្រងជាន់ខ្ពស់ផ្នែកទីផ្សារ និង អភិវឌ្ឍន៍សាជីវកម្មនៃក្រុមហ៊ុនបច្ចេកវិទ្យា ដែលទើបចាប់ផ្តើម និង NASDQ ជាអាជីវកម្ម ពាណិជ្ជកម្មអេឡិចត្រូនិចដែលមានចុះបញ្ជីទីផ្សារភាគហ៊ុន ។

លោក Joshua ទទួលបានសញ្ញាបត្រអនុបណ្ឌិតពីសាកលវិទ្យាល័យ Harvard Business School ឆ្នាំ១៩៩៨ និងសញ្ញាបត្របរិញ្ញាបត្រកិត្តិយសពី Harvard University ក្នុងឆ្នាំ១៩៩២ ។



មីង សាវង្ស កំពុងដកត្រកួន
នៅខាងមុខផ្ទះរបស់គាត់
អតិថិជនខេត្តសៀមរាប

# គណៈគ្រប់គ្រង



# គណៈគ្រប់គ្រង



## ផុន សុថានី
### អគ្គនាយិកាប្រតិបត្តិ

លោកស្រី ផុន សុថានី បានចាប់ផ្តើមអាជីពជាមួយ អង្គការទស្សនៈពិភពលោក ជាសវនករផ្ទៃក្នុង នៅក្នុងឆ្នាំ ២០០២។ ចាប់តាំងពីពេលនោះមក លោកស្រី មានការរីកចម្រើនយ៉ាងលឿនជាមួយ តួនាទីជាច្រើន រួមមានការគ្រប់គ្រងការបង្កើត គម្រោង ការបង្កើតសំណើរ (Propsoal Develo pment) ការពិនិត្យការរីកចម្រើន និងការកសាង ទំនាក់ទំនងជាមួយម្ចាស់ជំនួយ។
នៅឆ្នាំ២០០៧ លោកស្រី បានក្លាយជាប្រធានផ្នែក អភិវឌ្ឍន៍ពាណិជ្ជកម្មនៃ វីសិនហ្វាន់ កម្ពុជា ដែល លោកស្រីទទួលខុសត្រូវផ្នែករកមូលនិធិ ផ្នែកទីផ្សារ ផ្នែកទំនាក់ទំនង និងអភិវឌ្ឍន៍ផលិតផល ។ ឆ្នាំ ២០០៨ លោកស្រីផ្លាស់ទៅក្រុមហ៊ុន វីង ដែលនៅ ទីនោះ លោកស្រីបានបង្កើតផែនការយុទ្ធសាស្ត្រ និងគ្រប់គ្រងការលក់ រួមទាំងការលើកទឹកចិត្តនិង ពង្រីកភ្នាក់ងារលក់ជាង៩០០នាក់ ។ លោកស្រី សុថានីបានចូលបម្រើការជាមួយ ហ្វីស ហ្វាយនែន នៅឆ្នាំ ២០១១ ជានាយិកាផ្នែកហិរញ្ញវត្ថុ ហើយ ត្រូវបានតែងតាំងជាអគ្គនាយិកាប្រតិបត្តិ នៅខែ សីហា ឆ្នាំ ២០១៤ ។
លោកស្រី សុថានី បានទទួលបរិញ្ញាបត្រគ្រប់គ្រង ផ្នែកគណនេយ្យ និងបានបន្តអនុបណ្ឌិតអភិវឌ្ឍអង្គ-ភាពក្នុងការគ្រប់គ្រងកម្ចីខ្នាតតូច ។

## នីន និត្យា
### នាយកហិរញ្ញវត្ថុ

លោក និត្យា បានបញ្ចប់ផ្នែក រដ្ឋបាលអាជីវកម្ម ពី សាកលវិទ្យាល័យ កាលីហ្វ័រនៀរ នៅ Berkeley ហើយបានទទួលអាជ្ញាបណ្ណបញ្ជាក់ជាគណនេយ្យ-ករសាធារណៈ (CPA) ក្នុងឆ្នាំ ២០០៩ ។
ដោយរួមបញ្ចូលរយៈពេលបំពេញការងារ ២ឆ្នាំ ជាមួយក្រុមហ៊ុន Fortune 500 និត្យា មានបទ ពិសោធន៍ការងារជាង ៨ឆ្នាំ ក្នុងការគ្រប់គ្រង គណនេយ្យ សវនកម្ម គ្រប់គ្រងហានិភ័យ រួមទាំងការ ធ្វើផែនការ និងវិភាគហិរញ្ញវត្ថុ នៅក្នុងវិស័យជាច្រើន រួមទាំងវិស័យហិរញ្ញវត្ថុ ។





## ហេង សក្តា
### ប្រធាននាយកដ្ឋានប្រតិបត្តិការ

លោក ហេង សក្តា ជាសមាជិកដែលបានធ្វើការយូរ ជាងគេជាមួយ ហ្វីស ហ្វាយនែន ។ ចាប់ផ្តើមដំបូង ជាមន្ត្រីរដ្ឋបាលឥណទាននៅឆ្នាំ ២០០៩ ពេលដែល ហ្វីស ហ្វាយនែន ទទួលបានអាជ្ញាប័ណ្ណ របស់ ខ្លួន ។ លោក សក្តា បានរីកចម្រើនជាមួយតួនាទី មួយចំនួន និងបានទទួលការតែងតាំងជាប្រធាន សាខាភ្នំពេញនៅឆ្នាំ ២០១៣ និងជាប្រធាននាយ-កដ្ឋានប្រតិបត្តិការនៅខែ ឧសភា ឆ្នាំ ២០១៥។ គាត់ មានចំណេះដឹងទូលំទូលាយអំពីក្រុងភ្នំពេញ ព្រោះ គាត់រស់នៅទីនេះពេញមួយជីវិតរបស់គាត់ តែគាត់ក៏ មានបទពិសោធន៍ ធ្វើដំណើរទៅក្រៅប្រទេសផងដែរ ។ លោក សក្តា ទទួលបានបរិញ្ញាបត្រពីរ គឺគណនេយ្យ ហិរញ្ញវត្ថុ និង ភាសាបារាំង ។ បច្ចុប្បន្នគាត់កំពុង បញ្ចប់អនុបណ្ឌិតគ្រប់គ្រងហានិភ័យ ផ្នែកធានា រ៉ាប់រង ហិរញ្ញវត្ថុ និងធនាគារ ។

## ភួន សេដ្ឋា
### ប្រធានផ្នែកឥណទាន

លោក ភួន សេដ្ឋា បានទទួលបរិញ្ញាបត្រគ្រប់គ្រង ពីសាកលវិទ្យាល័យបាត់ដំបងក្នុងឆ្នាំ២០១២។ មុន មកកាន់ ហ្វីស ហ្វាយនែន គាត់បានបម្រើការនៅ វិសិនហ្វាន់រយៈពេល៥ឆ្នាំ២ខែមានតួនាទីជាប្រធាន សាខាខេត្ត ប្រធានសាខាស្រុក និងមន្ត្រីបម្រើ អតិថិជន។ គាត់ក៏បានបម្រើការជាគ្រូរូបវិទ្យានិង គណិតវិទ្យានៅអនុវិទ្យាល័យរយៈពេល៣ឆ្នាំដែរ។ គាត់បានចូលរួមជាមួយ ហ្វីស ហ្វាយនែនក្នុងខែ មិនា ឆ្នាំ២០១៣ជាប្រធានសាខា ហើយបន្ទាប់ មកក៏ត្រូវបានតែងតាំងជាប្រធានផ្នែកឥណទាន។



# គណៈគ្រប់គ្រង



## សាំង វណ្ណឌី
### ប្រធានផ្នែកទីផ្សារ

លោក វណ្ណឌី បានទទួលបរិញ្ញាបត្រផ្នែកប្រព័ន្ធព័ត៌-មានវិទ្យាគ្រប់គ្រង ពីសាកលវិទ្យាល័យជាតិគ្រប់-គ្រងក្នុងឆ្នាំ២០០២។ មុនមកចូលរួមជាមួយ ហ្វីស ហ្វាយនែន គាត់បានបំរើការជាអ្នកសម្របសម្រួលផ្នែកទីផ្សារ និងទំនាក់ទំនងរយៈពេល ២ឆ្នាំ និងបន្ទាប់មកជាអ្នកគ្រប់គ្រងផ្នែកផលិតសម្ភារៈផ្សព្វផ្សាយជាង ៧ឆ្នាំ នៅ វីសិនហ្វាន់ កម្ពុជា ដែលគាត់ជាអ្នកគ្រប់គ្រង និងអភិវឌ្ឍន៍យុទ្ធសាស្រ្តប្រេនដ៏ និងយុទ្ធសាស្រ្តទំនាក់ទំនងទីផ្សារ។ លោក វណ្ណឌី ក៏មានបទពិសោធន៍ជាច្រើនឆ្នាំខាងផ្នែកផ្សព្វផ្សាយ និងអង្គការអន្តរជាតិផងដែរ។ គាត់ចូលរួមជាមួយ ហ្វីស ហ្វាយនែន ក្នុង ខែមីនា ឆ្នាំ២០១៦ ជាប្រធានផ្នែកទីផ្សារ។

## លឹម ស្ទហ្វីយ៉ា ហ្វាដែត
### ប្រធានផ្នែកអភិវឌ្ឍន៏ពាណិជ្ជកម្ម

អ្នកស្រី ហ្វាដែត បានបញ្ចប់បរិញ្ញាបត្រសេដ្ឋកិច្ចជំនាញផ្នែកគ្រប់គ្រង និងបច្ចុប្បន្ននេះកំពុងតែបន្តថ្នាក់អនុបណ្ឌិតនៅ សាកលវិទ្យាល័យ Limko-kwing ជំនាញហិរញ្ញវត្ថុ។ មុនមកចូលរួមជាមួយ ហ្វីស ហ្វាយនែន ធ្វើជាប្រធានផ្នែកអភិវឌ្ឍន៍ពាណិជ្ជកម្ម នាឆ្នាំ២០១៦ អ្នកស្រីបានចំណាយពេល៥ឆ្នាំធ្វើការនៅក្នុងប្រទេសកម្ពុជាក្នុងវិស័យហិរញ្ញវត្ថុ ក៏ដូចជា វិស័យឧបករណ៍អេឡិចត្រូនិច ហើយបន្ទាប់មកក៏បានចំណាយពេល៤ឆ្នាំធ្វើការជាអ្នកស្ម័គ្រចិត្តផ្នែកមូលនិធិនិងសង្គមកិច្ចនៅប្រទេសសឹង្ហបុរី។ អ្នកស្រីមានជំនាញផ្នែក លក់ ទីផ្សារ ទំនាក់ទំនង ការប្រមូលមូលនិធិ គ្រប់គ្រងគម្រោង និងទំនាក់ទំនងសាធារណៈ។





## ច្រឹក ស៊ីណេត
### ប្រធានផ្នែកព័ត៌មានវិទ្យា

លោក ស៊ីណេត បានបម្រើការអស់រយៈពេលជាង១០ឆ្នាំ ក្នុងកិច្ចការស្ថាបនា និងអនុវត្តប្រព័ន្ធកុំព្យូទ័រ អនុវត្តសុវត្ថិភាពព័ត៌មានវិទ្យា គ្រប់គ្រងប្រព័ន្ធព័ត៌មាន យុទ្ធសាស្រ្តព័ត៌មានវិទ្យា និងអនុវត្តគំរោងជាមួយស្ថាប័នមីក្រូហិរញ្ញវត្ថុ និងធនាគារ ។ គាត់បានចូលរួម ហ្វីស ហ្វាន់នែនជាប្រធានគ្រប់គ្រងព័ត៌មានវិទ្យា នាខែមេសា ឆ្នាំ២០១៦។ មុនមកកាន់ ហ្វីស ហ្វាយនែន គាត់ជាប្រធានគាំទ្រកម្មវិធីព័ត៌មានវិទ្យា ដែលមានតួនាទីសម្របសម្រួល រវាងបុគ្គលិកបច្ចេកទេសព័ត៌មានវិទ្យានិងបុគ្គលិកផ្នែកអាជីវកម្ម នៅអម្រឹតរយៈពេល១ឆ្នាំ និងធ្លាប់ជាប្រធានគាំទ្រកម្មវិធីនិងបច្ចេកទេសនៅ វិសិនហ្វាន់កម្ពុជា។ គាត់បានទទួលបរិញ្ញាបត្រព័ត៌មានវិទ្យា ពីសាកលវិទ្យាល័យមួយនៅក្រុងភ្នំពេញ។

## វ៉េត វរលក្ខណ៍
### ប្រធានផ្នែកហិរញ្ញវត្ថុ

អ្នកស្រី វរលក្ខណ៍ មានបទពិសោធន៍ជាង៧ឆ្នាំ ផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ ។ វរលក្ខណ៍ ធ្លាប់បម្រើការងារនៅតាមក្រុមហ៊ុនគណនេយ្យ ក្រុមហ៊ុនធានារ៉ាប់រង និងអាជីវកម្មទូទៅ ។ អ្នកស្រី ចូលបម្រើការងារនៅក្នុង ហ្វីស ហ្វាយនែន នាឆ្នាំ២០១២។ វរលក្ខណ៍ បានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រផ្នែកហិរញ្ញវត្ថុ និងធនាគារ អនុបណ្ឌិតផ្នែកគ្រប់គ្រងពាណិជ្ជកម្ម និង បច្ចុប្បន្នកំពុងបន្តការសិក្សាថ្នាក់ ACCA ។



# គណៈគ្រប់គ្រង



## ឈួ សំបូរ
### ប្រធានសវនកម្មផ្ទៃក្នុង

លោក សំបូរ មានបទពិសោធន៍ជាង៦ឆ្នាំក្នុងការងារធានារ៉ាប់រង និងជាសវនករ។ គាត់បានចាប់ផ្ដើមអាជីពរបស់គាត់ដំបូងនៅ PriceWaterhouse Coopers (PwC) កម្ពុជា ធ្វើជាអ្នកជំនួយការសវនករ បន្ទាប់មកជាសវនករជាន់ខ្ពស់រយៈពេល៤ឆ្នាំ ចាប់តាំងពីឆ្នាំ២០០៧។ បន្ទាប់មកលោកក៏ផ្លាស់មក ហ្វីស ហ្វាយនែន ធ្វើជាសវនករជាន់ខ្ពស់ និងបន្ទាប់មកជាប្រធានគ្រប់គ្រងសវនករ បន្ទាប់ពីបានបញ្ចប់ការសិក្សាអនុបណ្ឌិតរយៈពេល២ឆ្នាំផ្នែកហិរញ្ញវត្ថុពីប្រទេស ញូវហ្សេលេន។ លោក សំបូរ បានទទួលបរិញ្ញាបត្រនិងអនុបណ្ឌិតផ្នែកហិរញ្ញវត្ថុ ហើយបច្ចុប្បន្ននេះកំពុងតែបន្តរយក ACCA/CPA។



## ស្រេង ស្រីពៅ
### ប្រធានផ្នែក រដ្ឋបាលនិងធនធានមនុស្ស

អ្នកស្រី ស្រីពៅ បានទទួលបរិញ្ញាបត្រផ្នែកគណនេយ្យ និងអនុបណ្ឌិតផ្នែកគ្រប់គ្រងអាជីវ-កម្ម។ អ្នកស្រី មានបទពិសោធន៍ជាង៨ឆ្នាំ ផ្នែកធនធានមនុស្ស និងរដ្ឋបាល ទាំងក្នុងស្ថានប័នមិនរកប្រាក់ចំណេញ និងស្ថាប័នឯកជន។ មុនមកចូលរួមជាមួយ ហ្វីស ហ្វាយនែន ជាប្រធានផ្នែករដ្ឋបាលនិងធនធានមនុស្សនៅ ខែតុលា ឆ្នាំ២០១៦ អ្នកស្រីបានបំរើការជាមន្ត្រីធនធានមនុស្ស និងជាអ្នកសម្របសម្រួលនៅមន្ទីរពេទ្យព្រះសីហនុ មជ្ឈមណ្ឌលនៃសេចក្ដីសង្ឃឹមពិភពលោក ដែលអ្នកស្រីមានតួនាទីជាអ្នករើសបុគ្គលិកគ្រប់គ្រងការវាយតម្លៃការងារ ការហ្វឹកហាត់ និងអភិវឌ្ឍន៍ប្រព័ន្ធព័ត៌មានធនធានមនុស្ស ទំនាក់ទំនងបុគ្គលិក អត្ថប្រយោជន៍បុគ្គលិក និងសំណង។



## ស៊ាន ម៉េងសែ
### ប្រធានផ្នែកបណ្ដុះបណ្ដាល និងអភិវឌ្ឍ

ម៉េងសែ មានការរីកចម្រើនខ្ពស់ក្នុងអាជីពការ-ងារ ។ លោកបានប្រលូកចូលក្នុងវិស័យការងារបានជាង១០ឆ្នាំ ដោយចាប់ផ្ដើមពីកម្រិតបុគ្គលិកធម្មតា រហូតដល់កម្រិតគ្រប់គ្រងក្នុងផ្នែកបណ្ដុះបណ្ដាល និងអភិវឌ្ឍ និងផ្នែកគ្រប់គ្រងធនធានមនុស្ស ដោយលោកមានបទពិសោធន៍ និងជំនាញពាក់ព័ន្ធនឹងផ្នែកជ្រើសរើសបុគ្គលិក បង្កើតគោលនយោបាយធនធានមនុស្ស រដ្ឋបាលបុគ្គលិក សម្របសម្រួលកិច្ចការធនធានមនុស្ស សំណងទូទាត់។ល។ លោកមានអត្តចរិកល្អប្រសើរ មានភាពអត់ធ្មត់ និងការតាំងចិត្តខ្ពស់។ អំពីការសិក្សា លោកបានទទួលអាហារូបករណ៍កម្រិតបរិញ្ញាបត្រពីសាកលវិទ្យាល័យជាតិគ្រប់គ្រងក្នុងឆ្នាំ២០០០ និងបានបញ្ចប់បរិញ្ញាបត្រផ្នែកគ្រប់គ្រងក្នុងឆ្នាំ២០០៤ និងបញ្ចប់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងក្នុងឆ្នាំ ២០០៩។



## អ៊ិន ឈួន
### ប្រធានសាខាបាត់ដំបង

លោក ឈួន បានទទួលបរិញ្ញាបត្រផ្នែកធនាគារ និងហិរញ្ញវត្ថុពីសាកលវិទ្យាល័យគ្រប់គ្រង និងវិទ្យាសាស្ត្រសេដ្ឋកិច្ចក្នុងឆ្នាំ២០១២។ មុនចូលមក ហ្វីស ហ្វាយនែន គាត់បានបម្រើការនៅ វិសិនហ្វាន់ រយៈពេល៨ឆ្នាំ ជាអ្នកគ្រប់គ្រងជាន់ខ្ពស់សាខាស្រុក មន្ត្រីជាន់ខ្ពស់ផ្នែកហានិភ័យ មន្ត្រីជាន់ខ្ពស់ផ្នែកគុណភាពធានារ៉ាប់រង និងមន្ត្រីឥណទាន។ លោក ឈួន មានតួនាទីយ៉ាងសំខាន់ក្នុងការគ្រប់គ្រងការរីកចម្រើនផលបត្រឥណទាន និងការគ្រប់គ្រងហានិភ័យរបស់សាខា។ គាត់បានចូលរួមជាមួយ ហ្វីស ហ្វាយនែន ក្នុងឆ្នាំ២០១៥ ជាប្រធានក្រុមមន្ត្រីប្រឹក្សាឥណទាន និងបន្ទាប់មកជាប្រធានសាខា។

FIRST FINANCE


អាគារលេខ A15-17 សង្កាត់ ទំនប់ទឹក ខណ្ឌចំការមន
ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ: 023 997 937
អ៊ីមែល: info@firstfinance.biz
វិបសាយ: www.firstfinance.biz